មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ២០១៦

## សៀវភៅណែនាំអំពី

# ធុរកិច្ចនិងសិទ្ធិមនុស្សនៅកម្ពុជា




ឧបត្ថម្ភដោយ

Fair Green and Global Alliance

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអាក់សិនអេត ប្រចាំនៅកម្ពុជា

*សៀវភៅណែនាំអំពីធុរកិច្ចនិងសិទ្ធិមនុស្សនៅកម្ពុជា* ("សៀវភៅណែនាំ") គឺជាសមិទ្ធផលរបស់ "គម្រោងពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលក្នុងការតស៊ូមតិ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្សពីសំណាក់ក្រុមហ៊ុនសាជីវកម្មក្នុងវិស័យដីធ្លី" ដែលជាគម្រោងធុរកិច្ចនិងសិទ្ធិមនុស្សអនុវត្តរួមគ្នាដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") និងអង្គការអាក់សិនអេតប្រចាំនៅកម្ពុជា។ គម្រោងនេះមានគោលបំណងលើកកម្ពស់ឱ្យមានការគោរពសិទ្ធិមនុស្សកាន់តែច្រើនឡើងនៅក្នុងចំណោមក្រុមហ៊ុនសាជីវកម្ម ដែលធ្វើប្រតិបត្តិការក្នុងវិស័យដីធ្លីនៅកម្ពុជា។ គម្រោងនេះនឹងត្រូវអនុត្តក្នុងរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២០ ដោយទទួលបានការគាំទ្រផ្នែកថវិកាពីសម្ពន្ធភាពសកលដើម្បីយុត្តិធម៌ និងបរិស្ថាន (Fair Green and Global Alliance) ដែលជាសម្ពន្ធអង្គការសង្គមស៊ីវិលនៃប្រទេសហូឡង់ ផ្តោតសំខាន់ទៅលើក្រុមប្រតិបត្តិរបស់ក្រុមហ៊ុនសាជីវកម្ម ពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងប្រព័ន្ធហិរញ្ញវត្ថុ និងពន្ធដារ។

ខ្លឹមសារទាំងមូលនៃសៀវភៅនេះជាទំនួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក និងពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់សម្ពន្ធភាពសកលដើម្បីយុត្តិធម៌ និងបរិស្ថានដែលជាសម្ពន្ធអង្គការសង្គមស៊ីវិលនៃប្រទេសហូឡង់ទេ។

ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ពន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឱ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសមភាព និងត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។

ចក្ខុវិស័យរបស់អង្គការអាក់សិនអេត គឺចង់បានពិភពលោកមួយដែលគ្មានភាពក្រីក្រ និងភាពអយុត្តិធម៌ ដែលក្នុងនោះមនុស្សគ្រប់រូបទទួលបានសិទ្ធិរស់រានមានជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរ។

## សំណួរ និងមតិយោបល់ត្រឡប់

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីសៀវភៅណែនាំនេះ ឬប្រសិនបើអ្នកចង់ផ្តល់មតិយោបល់ណាមួយ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ឬ សូមទាក់ទងតាមរយៈអាសយដ្ឋាន ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា។

ទូរសព្ទ ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១ ឬ ទូរសារ ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០២

គេហទំព័រ ៖ www.cchrcambodia.org

BY NC SA

# មាតិកា

ទំព័រ


**អក្សរកាត់**......iv
**និយមន័យ**......vi
**សេចក្តីផ្តើម**......1
អំពីសៀវភៅណែនាំនេះ......1
ហេតុអ្វីបានជាសៀវភៅណែនាំនេះមានសារៈសំខាន់?......1
១. សេចក្តីផ្តើមស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស......3
១.១ អ្វីទៅជាសិទ្ធិមនុស្ស?......3
១.២ តើសិទ្ធិមនុស្សត្រូវបានការពារដោយរបៀបណា?......5
១.២.១ សិទ្ធិមនុស្សក្នុងច្បាប់ជាតិ......5
១.២.២ សិទ្ធិមនុស្សក្នុងច្បាប់អន្តរជាតិ......7
១.៣ សិទ្ធិមនុស្សនៅក្នុងបរិបទធុរកិច្ច......9
១.៣.១ ធុរកិច្ចនិងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា......9
១.៣.២ សិទ្ធិ និងការទទួលខុសត្រូវ......11
១.៣.៣ ធុរកិច្ចនិងសិទ្ធិមនុស្ស ធៀបនឹងការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម......12
២. គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស......14
២.១ តើអ្វីជាគោលការណ៍ណែនាំ?......14
២.២ កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារសិទ្ធិមនុស្ស......15
២.៣ ទំនួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស......17
២.៤ ការផ្តល់ដំណោះស្រាយ......21
២.៥ ផលប្រយោជន៍នៃគោលការណ៍ណែនាំ......23
២.៥.១ តើគោលការណ៍ណែនាំមានប្រយោជន៍យ៉ាងដូចម្តេចខ្លះ?......23
៣. គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ......26
៣.១ តើគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ គឺជាអ្វី?......26
៣.២ តើគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិនិយាយអ្វីខ្លះអំពីបញ្ហាសិទ្ធិមនុស្ស?......27
៣.៣ ការប្រើប្រាស់គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ នៅក្នុងស្ថានភាពជាក់ស្តែង......28
៣.៤ ការអនុវត្តគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ នៅក្នុងបរិបទកម្ពុជា......32
៤. គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់......35

៤.១ តើគោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ គឺជាអ្វី? ..... 35
៤.២ តើអង្គការសង្គមស៊ីវិលអាចប្រើប្រាស់គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ បានដោយរបៀបណា? ..... 37
៤.៣ ការប្រើប្រាស់គោលការណ៍ណែនាំស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ ដើម្បីការពារសិទ្ធិមនុស្ស ..... 38
៤.៤ អភិបាលកិច្ចល្អនៃការកាន់កាប់ក្នុងស្ថានភាពជាក់ស្តែង ..... 39
**ឯកសារយោង ..... 42**

# អក្សរកាត់

| | |
|---|---|
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ស៊ី.អេស.អ | ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ (វិសោធនកម្ម) |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| វ.ប.ប | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន |
| ស.ដ.ស | សម្បទានដីសេដ្ឋកិច្ច |
| អ.ស.ក | អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ |
| សៀវភៅណែនាំ | សៀវភៅណែនាំនេះមានចំណងជើងថា *"សៀវភៅណែនាំអំពីធុរកិច្ចនិងសិទ្ធិមនុស្សនៅកម្ពុជា"* |
| គោលការណ៍ណែនាំ | គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.អ.ស.ស.ស.វ | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ស.ព.ជ | សហគ្រាសពហុជាតិ |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| ស្ថាប័នបង្គោលថ្នាក់ជាតិ | ស្ថាប័នបង្គោលថ្នាក់ជាតិសម្រាប់គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ |
| អូអ៊ីស៊ីឌី (OECD) | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ |
| គោលការណ៍ អូអ៊ីស៊ីឌី | គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ |
| ស.ស.ស.ម | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |

| | |
|---|---|
| វីជីជីធី (VGGT) | គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិ ស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងជាតិ |

# និយមន័យ

| | |
|---|---|
| គណនេយ្យភាព | សំដៅលើកាតព្វកិច្ចមន្ត្រីសាធារណៈ ដែលត្រូវធ្វើសេចក្តីរាយការណ៍អំពីការប្រើប្រាស់ធនធានរបស់ជាតិ និងដែលអាចឆ្លើយតបដល់សាធារណជនចំពោះការខកខានក្នុងការបំពេញមុខងាររបស់ខ្លួនដូចដែលបានកំណត់។ ដើម្បីធានាគណនេយ្យភាព រដ្ឋត្រូវឱ្យបុគ្គល ភ្នាក់ងារសាធារណៈ និងតួអង្គមិនមែនរដ្ឋទាំងឡាយទទួលខុសត្រូវចំពោះសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួនដោយយោងទៅតាមគោលការណ៍នីតិរដ្ឋ។ |
| តម្លាភាព | សំដៅលើភាពដែលសាធារណជនអាចស្វែងរកបាននូវឯកសារ ឬព័ត៌មានទាំងឡាយដែលទាក់ទងនឹងសេចក្តីសម្រេច និងការអនុវត្តមុខងាររបស់ស្ថាប័នរដ្ឋ។ ក្នុងន័យនេះ ត្រូវមានការកំណត់ឱ្យបានច្បាស់លាស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវគោលនយោបាយ ច្បាប់ បែបបទនីតិវិធី និងសេចក្តីសម្រេចចិត្តជាភាសាខ្មែរ និងក្នុងទម្រង់ដែលសាធារណជនអាចស្វែងរកបាន។ |
| ការអភិវឌ្ឍប្រកបដោយចីរភាព | សំដៅលើការធ្វើឱ្យរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋយូរអង្វែង ដោយពុំមានការបំផ្លិចបំផ្លាញធនធានធម្មជាតិនានា ដែលអាចជាការប្រឈមដល់មនុស្សជំនាន់ក្រោយៗទៀត។ |
| អភិបាលកិច្ច | សំដៅលើការប្រើប្រាស់សិទ្ធិអំណាចរបស់អាជ្ញាធររដ្ឋក្នុងការគ្រប់គ្រង និងបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋរបស់ខ្លួន។ |
| សហគ្រាសពហុជាតិ | សំដៅលើសហគ្រាស ឬក្រុមហ៊ុនដែលមានទីស្នាក់ការនៅក្នុងប្រទេសមួយ តែមានប្រតិបត្តិការនៅក្នុងប្រទេសជាច្រើនផ្សេងទៀត។ |
| សហគ្រាសពាណិជ្ជកម្ម | សំដៅលើធុរកិច្ចទាំងអស់ ទាំងជាទម្រង់ឆ្លងដែន និងទម្រង់ដទៃទៀត ដោយមិនគិតពីវិស័យ ឬប្រទេសដែលសហគ្រាសពាណិជ្ជកម្មនោះតាំងនៅ ឬធ្វើប្រតិបត្តិការ និងដោយមិនគិតពីទំហំ ទម្រង់ ឬរចនាសម្ពន្ធរបស់សហគ្រាសពាណិជ្ជកម្មនោះឡើយ។ |
| ការទទួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម | សំដៅលើការអនុវត្ត ឬប្រតិបត្តិការរបស់ធុរកិច្ច ដែលពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមនានាដែលផ្តល់ផលប្រយោជន៍ដល់សង្គម។ ការអនុវត្តទាំងនេះអាចមានពីតាមរយៈការផ្តល់វិភាគទានខ្លះរបស់សាជីវកម្មទៅមូលនិធិសប្បុរសផ្សេងរហូតដល់ការអនុវត្តប្រតិបត្តិការបៃតង ដោយមានការគិតគូរពីបញ្ហាបរិស្ថាន ជាដើម។ |
| ធុរកិច្ច | សំដៅលើរាល់សកម្មភាព ឬទម្រង់នៃការវិនិយោគ ឬការធ្វើអាជីវកម្ម ដើម្បីស្វែងរកប្រាក់ចំណេញ។ |
| សាជីវកម្ម | សំដៅលើក្រុមហ៊ុន ឬសហគ្រាសដែលមានទ្រង់ទ្រាយធំ ហើយដែលមានការចុះបញ្ជី និងការទទួលស្គាល់តាមផ្លូវច្បាប់ក្នុងការប្រតិបត្តិការដើម្បីរកប្រាក់ចំណេញ។ |

| | |
|---|---|
| នីតិរដ្ឋ | សំដៅលើប្រព័ន្ធនៃការគ្រប់គ្រងប្រទេសមួយដោយប្រើច្បាប់ និងគោលការណ៍ដែលមនុស្សគ្រប់រូប និងស្ថាប័ននានាស្ថិតនៅក្រោមច្បាប់ ហើយច្បាប់ត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះមនុស្សគ្រប់រូប និងស្ថាប័នទាំងនេះ។ |
| ច្បាប់ | ក្នុងន័យចង្អៀត សំដៅលើអត្ថបទច្បាប់ទាំងឡាយណាត្រូវបានអនុម័តដោយរដ្ឋសភា ពិនិត្យដោយព្រឹទ្ធសភា និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ។ ជាធម្មតា រាជរដ្ឋាភិបាលជាអ្នកព្រាងច្បាប់ (គេហៅថា សេចក្តីព្រាងច្បាប់) រីឯសភាមានតួនាទីស្នើឱ្យអង្គសភាធ្វើច្បាប់ (គេហៅថា សេចក្តីស្នើច្បាប់)។ |
| ព្រះរាជក្រម | សំដៅលើព្រះរាជកិច្ចរបស់ព្រះមហាក្សត្រ ដែលមានភារៈក្នុងការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់ ព្រមទាំងសន្ធិសញ្ញាអន្តរជាតិដែលសភាអនុម័ត ក្រោយរាជរដ្ឋាភិបាលចុះហត្ថលេខាឯកភាព។ |
| ព្រះរាជក្រឹត្យ | សំដៅលើព្រះរាជកិច្ចរបស់ព្រះមហាក្សត្រ ដែលទ្រង់ធ្វើទៅក្នុងទម្រង់នៃកិច្ចរដ្ឋបាលក្រោយមានសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ ឧទាហរណ៍ ព្រះរាជក្រឹត្យតែងតាំងឥស្សរជនជាន់ខ្ពស់ណាម្នាក់។ |
| អនុក្រឹត្យ | សំដៅលើទម្រង់នៃកិច្ចរដ្ឋបាល ដែលរាជរដ្ឋាភិបាលចេញជាបទបញ្ជា ឬសេចក្តីសម្រេចអ្វីមួយ ហើយដែលត្រូវចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ ជាគោលការណ៍ អនុក្រឹត្យស្ថិតនៅក្រោមច្បាប់ ហើយខ្លឹមសារនៃអនុក្រឹត្យនេះមិនអាចផ្ទុយពីច្បាប់បានទេ។ |
| ប្រកាស | សំដៅលើសេចក្តីសម្រេច ដែលចេញដោយសមាជិករាជរដ្ឋាភិបាល ដែលជាប្រធានស្ថាប័ន។ ជាគោលការណ៍ ប្រកាសត្រូវស្ថិតនៅក្រោមច្បាប់ និងអនុក្រឹត្យ។ |

# សេចក្តីផ្តើម

## អំពីសៀវភៅណែនាំនេះ

សៀវភៅណែនាំនេះ បង្កើតឡើងសម្រាប់ណែនាំអំពីធុរកិច្ចនិងសិទ្ធិមនុស្ស ជាពិសេសនៅក្នុងវិស័យដីធ្លីនៅកម្ពុជា និងការអនុវត្តលិខិតុបករណ៍សំខាន់ៗចំនួនបីស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ៖ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ("គោលការណ៍ណែនាំ") គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ និងគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់។ សៀវភៅណែនាំនេះ គឺសម្រាប់អង្គការសង្គមស៊ីវិល មន្ត្រីរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ក្រុមហ៊ុន សកម្មជន និងកម្មករផ្សេងទៀតដែលទទួលរងផលប៉ះពាល់ដោយសារការបំពានលើសិទ្ធិមនុស្សរបស់អាជីវកម្មក្នុងវិស័យដីធ្លី និងសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ចំពោះធុរកិច្ចនិងសិទ្ធិមនុស្ស។

យើងសង្ឃឹមថា សៀវភៅនេះនឹងអាចជួយជំរុញដល់ការត្រួតពិនិត្យដ៏ត្រឹមត្រូវលើបញ្ហាសិទ្ធិមនុស្ស និងទទួលយកនូវគំនិតដែលថាក្រុមហ៊ុនសាជីវកម្មមានកាតព្វកិច្ចក្នុងការបង្កើត និងអនុវត្តគោលនយោបាយទាំងឡាយពាក់ព័ន្ធនឹងការទទួលត្រូវចំពោះសង្គមរបស់ក្រុមហ៊ុនសាជីវកម្មស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

សៀវភៅណែនាំនេះបែងចែកជាបួនផ្នែកគឺ ផ្នែកទីមួយណែនាំអំពីបញ្ញត្តិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស។ ផ្នែកទីពីរពន្យល់អំពីគោលការណ៍ណែនាំ និងសារៈសំខាន់របស់គោលការណ៍ណែនាំ រួមទាំងរៀបរាប់អំពីរបៀបដែលធុរកិច្ច និងរដ្ឋអាចអនុវត្តក្របខណ្ឌ "ការការពារ ការគោរព និងដំណោះស្រាយ" និងបង្ហាញអំពីសារៈប្រយោជន៍នៃការអនុវត្តគោលការណ៍ណែនាំទាំងនេះ។ ផ្នែកទីបីពន្យល់អំពីគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ និងយន្តការដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការដែលពាក់ព័ន្ធ ព្រមទាំងស្ថាប័នបង្គោលថ្នាក់ជាតិ។ ផ្នែកចុងក្រោយបង្ហាញពីទិដ្ឋភាពសង្ខេបនៃគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្ម របស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងជាតិ។

សៀវភៅណែនាំនេះមានគោលបំណងបំពេញបន្ថែមដល់ការបណ្តុះបណ្តាលស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សដែល ម.ស.ម.ក រៀបចំតាមរយៈគម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស។

## ហេតុអ្វីបានជាសៀវភៅណែនាំនេះមានសារៈសំខាន់?

ធុរកិច្ចនិងសិទ្ធិមនុស្ស ដែលជាផ្នត់គំនិតមួយថ្មីទើបតែបានលេចឡើងក្នុងរយៈប៉ុន្មានទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ។ ក្នុងប្រទេសកម្ពុជានៅពេលដែលកំណើនសេដ្ឋកិច្ចខ្លាំង ការវិនិយោគអន្តរជាតិ និងការអភិវឌ្ឍកំពុងតែកើតឡើងដំណាលគ្នាក្នុងបរិយាកាសមួយ ដែលនីតិរដ្ឋមានភាពទន់ខ្សោយនៅឡើយនោះ ផ្នត់គំនិត

នេះរឹតតែមានសារៈសំខាន់ជាខ្លាំង ដោយសារតែធុរកិច្ចជាច្រើនដែលពាក់ព័ន្ធក្នុងវិស័យដីធ្លី មិនបានគោរពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើង។

សៀវភៅណែនាំនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពី ៖

- បញ្ហាសិទ្ធិមនុស្សទាក់ទងនឹងធុរកិច្ច
- តួនាទីរបស់រដ្ឋក្នុងការការពារសិទ្ធិមនុស្ស
- ការទទួលខុសត្រូវរបស់ធុរកិច្ចនៅក្នុងការគោរពសិទ្ធិមនុស្ស
- យន្តការសម្រាប់ដោះស្រាយបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងប្រតិបត្តិការធុរកិច្ចក្នុងវិស័យដីធ្លី
- សារៈសំខាន់របស់គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ ព្រមទាំងគោលការណ៍ស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនជាននេសាទ និងធនជានព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀងជាតិ។

យើងរំពឹងថា ការបង្កើនការយល់ដឹងនឹងជំរុញឱ្យរដ្ឋការពារសិទ្ធិមនុស្សទាក់ទងនឹងធុរកិច្ច ផ្តល់ហេតុផលការលើកទឹកចិត្ត និងការណែនាំច្បាស់លាស់ដល់ធុរកិច្ចក្នុងវិស័យដីធ្លីអំពីវិធីសាស្ត្រក្នុងការគោរពសិទ្ធិមនុស្សនៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន ព្រមទាំងពង្រឹងសិទ្ធិអំណាចដល់សង្គមស៊ីវិល សហគមន៍ និងកម្មករក្នុងការតស៊ូមតិ ដើម្បីសិទ្ធិរបស់ខ្លួនផ្ទាល់ទាក់ទងនឹងធុរកិច្ចនិងសិទ្ធិមនុស្ស។

# ១. សេចក្តីផ្តើមស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស

## ១.១ អ្វីទៅជាសិទ្ធិមនុស្ស?

សិទ្ធិមនុស្ស គឺជា**សិទ្ធិ និងសេរីភាពជាមូលដ្ឋានដែលប្រជាពលរដ្ឋទាំងអស់មាន ដោយមិនគិតអំពីសញ្ជាតិ ភេទ អាយុ ដើមកំណើតជាតិ ពូជសាសន៍ សាសនា ភាសា ឬឋានៈផ្សេងទៀតឡើយ។**

(សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)

**អ្នកមានសិទ្ធិមនុស្សដោយសារតែអ្នកជាមនុស្ស។**

សិទ្ធិមនុស្សមានលក្ខណៈសកល និងអនុវត្តដោយស្មើភាពគ្នាទៅលើមនុស្សទាំងអស់ មានន័យថាមនុស្សគ្រប់រូបមានសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិទាំងនោះដោយគ្មានការរើសអើង។ សិទ្ធិរបស់បុគ្គលម្នាក់មិនមានសារៈសំខាន់ជាងបុគ្គលណាម្នាក់ផ្សេងទៀតនោះទេ ហើយមិនមាននរណាម្នាក់អាចរំលោភសិទ្ធិរបស់អ្នកផ្សេងទៀតដោយសារតែពួកគេមានទ្រព្យជាង ធំជាង ខ្លាំងជាង ឬមានអំណាចជាងនោះទេ។

> **"មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ..."**
> **(មាត្រា ១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)**

សិទ្ធិមនុស្សមានលក្ខណៈសកល និងមិនអាចដកហូតបានទេ។ នេះមានន័យថា សិទ្ធិមនុស្សជាសិទ្ធិមូលដ្ឋានដែលត្រូវតែទទួលបានការការពារគ្រប់ពេលវេលាទាំងអស់។ សិទ្ធិមនុស្សគួរត្រូវបានគេគិតពិចារណា និងត្រូវបានគោរពដោយមនុស្សទាំងអស់ ប៉ុន្តែសម្រាប់អ្នកដែលមានអំណាចលើអ្នកដទៃត្រូវតែប្រតិបត្តិប្រកបដោយការប្រុងប្រយ័ត្នជាពិសេស។ នេះគឺដោយសារតែអំណាចដែលពួកគេមាននិងប្រើប្រាស់នោះមានសក្តានុពលខ្លាំងបំផុតក្នុងការបណ្តាលឱ្យមានការរំលោភបំពានសិទ្ធិមនុស្ស។ ឧទាហរណ៍ រដ្ឋាភិបាល ដែលមានតួនាទីសំខាន់ជាអ្នកបង្កើតច្បាប់ និងគោលនយោបាយដែលជះឥទ្ធិពលទៅលើមនុស្សក្នុងប្រទេសទាំងមូល ត្រូវយកចិត្តទុកដាក់ជាពិសេសដល់សិទ្ធិមនុស្ស។ ឧទាហរណ៍មួយអំពីវិធីដែលរដ្ឋាភិបាលមួយអាចធានាថាមានការគោរពសិទ្ធិមនុស្សនោះ គឺធ្វើឱ្យប្រាកដថាការអនុម័តច្បាប់ស្តីពីការងារណាមួយនឹងមិនមានការរើសអើងដោយអយុត្តិធម៌ទៅលើក្រុមមនុស្សណាមួយដូចជា ស្ត្រី ឬមនុស្សមកពីក្រុមជនជាតិភាគតិច។ ស្ថាប័នរដ្ឋទាំងអស់ក៏ត្រូវមានការប្រុងប្រយ័ត្នក្នុងការមិនបង្ក ឬរួមចំណែកដល់ការរំលោភបំពានសិទ្ធិមនុស្ស។ ឧទាហរណ៍ ប៉ូលីសស្ថិតនៅក្នុងតួនាទីមួយក្នុងការដកហូតសេរីភាពរបស់មនុស្ស ហើយត្រូវធានាថាការស៊ើបអង្កេតសមស្របត្រូវធ្វើឡើងមុនពេលចោទប្រកាន់មនុស្សពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ហើយពួកគេមិនត្រូវប្រើអំណាចតាមទំនើងចិត្តនោះទេ។

ឧទាហរណ៍សិទ្ធិមនុស្សមូលដ្ឋានមានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរូបភាពខាងក្រោម ៖




ប្រភព ៖ ម.ស.ម.ក

ធុរកិច្ច គឺជាស្ថាប័នណាមួយ ដែលប្រតិបត្តិសកម្មភាពក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ ហើយអាចមានទម្រង់ជាក្រុមហ៊ុនសាជីវកម្មពហុជាតិ ក្រុមហ៊ុនតូច ក្រុមហ៊ុនក្នុងស្រុក ឬសហគ្រាសលក្ខណៈគ្រួសារ។

ខណៈពេលដែលធុរកិច្ចអាចផ្តល់ប្រយោជន៍មួយចំនួនដល់សង្គម ដោយរាប់បញ្ចូលទាំងការបង្កើតការងារ ការបង្កើនកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចក៏ដោយ ក៏វាជាការសំខាន់ក្នុងការកត់សម្គាល់ថា ធុរកិច្ចក៏អាចបង្កឱ្យមានការរំលោភបំពានសិទ្ធិមនុស្សផងដែរ ដោយសារតែសកម្មភាពរបស់អាជីវកម្មអាចមានសក្តានុពលក្នុងការជះឥទ្ធិពលទៅលើជីវិតមនុស្សជាច្រើន។ ឧទាហរណ៍ ធុរកិច្ចផ្តល់ការងារដល់កម្មករ ហើយគួរធានាថាកម្មករទាំងនោះទទួលបានប្រាក់ខែ និងទទួលបានការប្រព្រឹត្តមកលើខ្លួនយ៉ាងត្រឹមត្រូវ។ ធុរកិច្ចជាច្រើនអនុវត្តសកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់ភូមិសាស្ត្រ ដែលមានភាពរសើប និងគួរខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីបញ្ចៀសការប៉ះពាល់សិទ្ធិរបស់ក្រុមមនុស្សងាយរងគ្រោះ ជាពិសេសសហគមន៍ជនជាតិដើមភាគតិច។



ប្រភព ៖ អាក់សិនអេត

សិទ្ធិមនុស្សមានសារៈសំខាន់ណាស់ ដោយសារតែវាអាចជួយយើងឱ្យមានភាពចុះសម្រុងជាមួយគ្នា និងរស់នៅក្នុងសង្គមមួយដែលកសាងចេញពីសេរីភាព យុត្តិធម៌ និងសន្តិភាព និងនៅក្នុងកន្លែងដែលមានការការពារ និងគោរពនីតិរដ្ឋ។ សិទ្ធិមនុស្សការពារយើង ប្រឆាំងនឹងមនុស្សដែលបង្កការរំខាន ឬការឈឺចាប់ដល់យើងមានន័យថា នៅពេលដែលមនុស្សមិនសូវបានដឹងអំពីសិទ្ធិមនុស្ស ការបំពាន ដូចជាការរើសអើង ភាពមិនសន្តោសប្រណី អយុត្តិធម៌ ការគាបសង្កត់ និងទាសភាព អាចកើតឡើងបាន។ លុះត្រាតែនៅពេលដែលមនុស្សយល់ដឹងថាអ្វីជាសិទ្ធិរបស់ខ្លួន ទើបពួកគេអាចការពារខ្លួន និងអ្នកដទៃបាន។

## ១.២ តើសិទ្ធិមនុស្សត្រូវបានការពារដោយរបៀបណា?

សិទ្ធិមនុស្សត្រូវបានកំណត់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ សិទ្ធិមនុស្សរួមបញ្ចូលទាំងសិទ្ធិ និងការទទួលខុសត្រូវ។ រដ្ឋគួរតែសន្មតភារកិច្ច និងការទទួលខុសត្រូវក្រោមច្បាប់អន្តរជាតិដើម្បីការពារ និងបំពេញសិទ្ធិមនុស្សទាំងឡាយ។ ស្របពេលគ្នានោះ មនុស្សគ្រប់រូបក៏មានសិទ្ធិ និងការទទួលខុសត្រូវដែរ មានន័យថា នៅពេលដែលយើងទទួលបានសិទ្ធិមនុស្សរបស់ខ្លួន យើងក៏គួរតែគោរពសិទ្ធិរបស់អ្នកដទៃដូចគ្នាដែរ។

### ១.២.១ សិទ្ធិមនុស្សក្នុងច្បាប់ជាតិ

ជំពូកទីបីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងអំពីសិទ្ធិមនុស្សរបស់ពលរដ្ឋខ្មែរ និងមានសរុបចំនួន ២០មាត្រា។ មាត្រាមួយនៅក្នុងជំពូកទីបី គឺមាត្រា៣១ ចែងថា ៖

*"ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ*

*ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។"*

ជាសំខាន់ នេះមានន័យថាប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនដោយស្មើភាពគ្នាចំពោះមុខច្បាប់ គឺសិទ្ធិត្រូវបានការពារដោយតុលាការ និងរដ្ឋាភិបាល។ ជាសំខាន់ដែរ ប្រយោគទីពីរខាងលើមានន័យថាគ្មានបុគ្គលណាម្នាក់ត្រូវប្រើសិទ្ធិរបស់ខ្លួនតាមវិធីណាមួយ ដែលធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃឡើយ។

មាត្រាផ្សេងទៀតក្នុងជំពូកទីបីនេះ ផ្តល់ព័ត៌មានបន្ថែមអំពីសិទ្ធិមនុស្សជាក់លាក់មួយចំនួនដែលប្រជាពលរដ្ឋខ្មែរគ្រប់រូបមានតាមច្បាប់រដ្ឋធម្មនុញ្ញ។ សិទ្ធិទាំងនេះរួមមានដូចខាងក្រោម ប៉ុន្តែមិនមែនមានតែត្រឹមប៉ុណ្ណេះទេ ៖

- សិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន (មាត្រា ៣២)
- សិទ្ធិបោះឆ្នោត (មាត្រា ៣៤)
- សិទ្ធិធ្វើបាតុកម្ម (មាត្រា ៣៧)
- សិទ្ធិធ្វើដំណើរ (មាត្រា ៤០) និង
- សិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី (មាត្រា ៤៤)

មានច្បាប់មួយចំនួនផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាដែលបង្កើតបន្ថែមលើសិទ្ធិមនុស្សជាមូលដ្ឋាន ដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងផ្តល់ការការពារទៅលើសិទ្ធិជាក់លាក់បន្ថែមទៀត។ ខាងក្រោមនេះជាបញ្ជីច្បាប់ទាំងនោះ ដោយភាគច្រើនអាចអនុវត្តបានចំពោះធុរកិច្ចនិងសិទ្ធិមនុស្ស។ ឧទាហរណ៍ ៖

- **ច្បាប់ស្តីពីកិច្ចការការពារបរិស្ថាន និងការគ្រប់គ្រប់ធនធានធម្មជាតិ** ឆ្នាំ១៩៩៦ មានបទប្បញ្ញត្តិ ដែលមានបំណងក្នុងការការពារបរិស្ថាន និងធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានជាសក្តានុពលនៃគម្រោងទាំងអស់ មុនពេលទទួលបានការអនុញ្ញាតពីរដ្ឋាភិបាល។
- **ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧** គ្របដណ្តប់ទៅលើរាល់ស្ថានភាពទាំងអស់ ដែលមានទំនាក់ទំនងរវាងនិយោជក និងនិយោជិត ព្រមទាំងបានការពារបន្ថែមដល់សិទ្ធិការងាររបស់កម្មករ។
- **ច្បាប់ស្តីពីភូមិបាល ឆ្នាំ២០០១** កំណត់អំពីកិច្ចការពារសិទ្ធិដីធ្លី និងអចលនទ្រព្យ។
- **ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២** ចែងពីបទប្បញ្ញត្តិដែលបង្កើតឡើងដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។
- **ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧** គ្រប់ដណ្តប់លើរាល់ស្ថានភាពទាក់ទងនឹងបញ្ហារដ្ឋប្បវេណីទាំងអស់ (ទាក់ទងនឹងទ្រព្យសម្បត្តិក្នុងចំណោមសាច់ញាតិ) ដើម្បីការពារសិទ្ធិបុគ្គល។
- **ច្បាប់ស្តីពីជលផល ឆ្នាំ២០០៧** មានបំណងលើកកម្ពស់ និងការពារជីវភាពរស់នៅរបស់សហគមន៍ដែលរស់នៅជិតប្រភពត្រី។

- **ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៧** លើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយនិរន្តរភាព ដើម្បីកុំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើជីវភាពរស់នៅ។
- **ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩** ចែងអំពីអំពើល្មើសដែលបង្កើតជាបទល្មើសព្រហ្មទណ្ឌក្នុងប្រទេសកម្ពុជា និងចែងអំពីច្បាប់សំខាន់ៗទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ និងចែងអំពីរបៀបដែលនគរបាលត្រូវប្រព្រឹត្តទៅលើជនសង្ស័យដែលបានប្រព្រឹត្តបទល្មើស។
- **ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០** រៀបរាប់អំពីរបៀបដកហូតដីសាធារណៈដែលអាចធ្វើឡើងប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌។
- **អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច** ចែងអំពីនីតិវិធីសម្រាប់ផ្តល់កម្មសិទ្ធិដីធ្លី និងការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិច ហើយវាជាឧបករណ៍ច្បាប់ដ៏សំខាន់មួយក្នុងការការពារសិទ្ធិមនុស្សរបស់ជនជាតិដើមភាគតិច។

## ១.២.២ សិទ្ធិមនុស្សក្នុងច្បាប់អន្តរជាតិ

សិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូបនៅក្នុងប្រទេសទាំងអស់ត្រូវបានការពារដោយច្បាប់អន្តរជាតិ។ ដើមកំណើតនៃការការពារសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ អាចមានឃើញនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិផ្ទាល់ ដែលក្នុងសេចក្តីផ្តើមបានចែងថាគោលបំណងរបស់អង្គការសហប្រជាជាតិគឺ *"អះអាងឡើងវិញអំពីជំនឿទៅលើសិទ្ធិមនុស្សជាសារវន្ត ទៅលើសេចក្តីថ្លៃថ្នូរ និងទៅលើតម្លៃរបស់មនុស្ស ទៅលើសិទ្ធិស្មើភាពគ្នារបស់បុរស និងស្ត្រី និងរបស់ជាតិទាំងឡាយ ទាំងធំទាំងតូច...។"*

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាឯកសារដំបូងគេ ដែលបានចែងអំពីសិទ្ធិមនុស្សរបស់មនុស្សទាំងអស់នៅក្នុងពិភពលោក។ ទោះបីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សមិនចងកាតព្វកិច្ចក៏ដោយ ក៏ឯកសារនេះត្រូវបានរដ្ឋចាត់ទុកជាសេចក្តីថ្លែងការណ៍ ដែលមានឥទ្ធិពលមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលបង្ហាញពីឆន្ទៈនយោបាយរឹងមាំរបស់រដ្ឋ។ បទប្បញ្ញត្តិរបស់សេចក្តីប្រកាសនេះត្រូវបានចាត់ទុកជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមួយ ហេតុដូច្នេះហើយ វាចងកាតព្វកិច្ចទៅលើគ្រប់រដ្ឋទាំងអស់។

ច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិតាមរយៈស្មារតីមាត្រា៣១ នៃរដ្ឋធម្មនុញ្ញដែលចែងថាប្រទេសកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងច្បាប់អន្តរជាតិដោយរាប់បញ្ចូលទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិផ្សេងទៀតថា ៖

> *"ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"*

កតិកាសញ្ញាអន្តរជាតិសំខាន់បំផុតចំនួនពីរ គឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ("ក.អ.ស.ស.ស.វ") ដែលរួមមានព័ត៌មានលម្អិតបន្ថែមទៀតស្តីពីសិទ្ធិ ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សហើយប្រទេសកម្ពុជាជាភាគីរបស់ច្បាប់អន្តរជាតិទាំងពីរនេះ។ សារៈសំខាន់នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺត្រូវចាត់ទុកជារួមថាជា **ច្បាប់អន្តរជាតិស្តីពីសិទ្ធិ**។ ក៏ប៉ុន្តែ ក្រៅពីឧបករណ៍ច្បាប់ដ៏សំខាន់ទាំងបីនេះ ក៏នៅមានប្រភពច្បាប់សិទ្ធិមនុស្សអន្តរជាតិផ្សេងមួយចំនួនទៀត ដែលការពារសិទ្ធិមនុស្ស ដោយរាប់បញ្ចូលទាំងពលរដ្ឋខ្មែរផង។ ខាងក្រោមនេះគឺជាបញ្ជីជម្រើសលិខិតុបករណ៍ច្បាប់អន្តរជាតិសំខាន់ៗមួយចំនួនបន្ថែមទៀត ៖

- **អនុសញ្ញាស្តីពីសិទ្ធិកុមារ** ចែងអំពីសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច សុខភាព និងវប្បធម៌របស់កុមារ។ ការអនុលោមត្រូវបានតាមដានដោយគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ។
- **អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រី** រួមមានបទប្បញ្ញត្តិហាមឃាត់ជាពិសេសកុំឱ្យមានការរើសអើង ឬបំពានសិទ្ធិមនុស្សរបស់ស្ត្រី។
- **អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍** រៀបរាប់អំពីបទប្បញ្ញត្តិដែលមានបំណងកាត់បន្ថយការរើសអើងពូជសាសន៍ និងលើកកម្ពស់ការសន្ដោសប្រណី និងការយោគយល់ដល់ពូជសាសន៍ទាំងអស់។
- **អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ** មានបំណងការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ។
- **អនុសញ្ញាអន្តរជាតិសម្រាប់ការការពារបុគ្គលគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ** រួមមានបទប្បញ្ញត្តិ ដែលផ្តោតទៅលើការទប់ស្កាត់ការបាត់ខ្លួនដោយបង្ខំ។

បន្ថែមពីលើលក្ខខណ្ឌចាំបាច់របស់លិខិតុបករណ៍ច្បាប់អន្តរជាតិ សមាជិកភាពរបស់ប្រទេសកម្ពុជានៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន") ក៏អាចឆ្លុះបញ្ចាំងថា ជាការបង្កើននូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលើកកម្ពស់សិទ្ធិមនុស្សដែរ។ តាមពិតទៅ ធម្មនុញ្ញអាស៊ានបញ្ជាក់ច្បាស់ថា គោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនរបស់អាស៊ានគឺ "*... លើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ...*។" បន្ថែមពីនេះទៀត នៅខែវិច្ឆិកា ឆ្នាំ២០១២ សមាជិកអាស៊ានទាំងអស់បានអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានដោយសំឡេងឯកច្ឆ័ន្ទ ដែលសេចក្តីប្រកាសនេះបញ្ជាក់ជាថ្មីឡើងវិញអំពីការប្តេជ្ញាចិត្តក្នុងការគោរពសិទ្ធិមនុស្សដូចចែងនៅក្នុងធម្មនុញ្ញអាស៊ាន និងចែងយ៉ាងពិស្តារនៅក្នុងគោលការណ៍សិទ្ធិមនុស្សទូទៅដែលសមាជិកបានចូលរួមគោរព។

ឥឡូវនេះ វាគួរតែមានភាពច្បាស់លាស់ហើយថា តាមពិតទៅមានយន្តការផ្នែកច្បាប់ជាច្រើនដែលស្វែងរកការការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សជាច្រើននោះ។ ឥឡូវនេះ យើងនឹងបន្តពិចារណាអំពីសិទ្ធិមនុស្សដែលពាក់ព័ន្ធជាពិសេសទៅនឹងបរិយាកាសធុរកិច្ចវិញម្តង។

## ១.៣ សិទ្ធិមនុស្សនៅក្នុងបរិបទធុរកិច្ច

ធុរកិច្ចនិងសិទ្ធិមនុស្ស សំដៅទៅលើការគោរពសិទ្ធិមនុស្សជាមូលដ្ឋានរបស់វិស័យឯកជន។ ស្ទើរតែរាល់សិទ្ធិមនុស្សទាំងអស់ អាចទទួលរងការប៉ះពាល់ពីសកម្មភាពធុរកិច្ច ដោយផ្ទាល់ ឬដោយប្រយោល។

ធុរកិច្ចអាចមានផលប៉ះពាល់វិជ្ជមានទៅលើសិទ្ធិមនុស្ស ដូចជាក្រុមហ៊ុន ដែលបង្កើតការងារសម្រាប់សហគមន៍មូលដ្ឋាន និងផ្តល់ប្រាក់ឈ្នួលសមរម្យ បានរួមចំណែកដល់សមត្ថភាពរបស់មនុស្សក្នុងការគាំទ្រខ្លួនពួកគេ។ ឧទាហរណ៍មួយទៀតគឺថា ប្រសិនបើក្រុមហ៊ុនមួយធ្វើការជាមួយរដ្ឋាភិបាល ឬអាជ្ញាធរមូលដ្ឋានដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន។ ផ្ទុយទៅវិញ សកម្មភាពធុរកិច្ចក៏អាចជះឥទ្ធិពលអវិជ្ជមានទៅលើសិទ្ធិមនុស្សផងដែរ ឧទាហរណ៍ នៅពេលដែលមនុស្សត្រូវបានគេបណ្តេញចេញពីផ្ទះសម្បែងដើម្បីបើកផ្លូវឱ្យមានការអភិវឌ្ឍធុរកិច្ច ឬនៅពេលកម្មករត្រូវបានគេបង្ខំឱ្យធ្វើការច្រើនម៉ោងដោយមិនមានការសម្រាក ដោយទទួលបានប្រាក់ឈ្នួលមិនសមរម្យ និងមិនគ្រប់គ្រាន់។

### ១.៣.១ ធុរកិច្ចនិងសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា

នៅប្រទេសកម្ពុជា ដែលវិស័យធុរកិច្ចត្រូវបានញាំញីដោយក្តីបារម្ភជាច្រើនពីបញ្ហាសិទ្ធិមនុស្ស ទស្សនៈជុំវិញធុរកិច្ចនិងសិទ្ធិមនុស្សគឺជាបញ្ហាចាំបាច់ជាពិសេស ប៉ុន្តែទស្សនៈនេះនៅថ្មីនៅឡើយ ហើយប្រជាពលរដ្ឋខ្មែរជាច្រើនមិនទាន់យល់ដឹងអំពីបញ្ហានេះនៅឡើយទេ។

ទស្សនទានស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សមានសារៈសំខាន់ជាពិសេសសម្រាប់វិស័យដីធ្លីនៅកម្ពុជា ដោយសារតែរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការជួលដីមួយក្នុងទំហំធំៗដើម្បីជាប្រយោជន៍ពាណិជ្ជកម្មតាមរយៈសម្បទានដីសេដ្ឋកិច្ច។ ជារឿយៗ ធុរកិច្ចពឹងផ្អែកលើការសន្យាក្លែងក្លាយ ការគំរាមកំហែង និងអំពើហិង្សាដើម្បីរំលោភយកដីពីប្រជាពលរដ្ឋងាយរងគ្រោះ។ ការរំលោភបំពាននេះមិនបញ្ចប់ត្រឹមការទទួលបានដីនោះទេ។ ជាលទ្ធផលក្រោយពីការរំលោភយកដីបែបនេះ ជាញឹកញាប់ក្រុមហ៊ុនសាជីវកម្មមានការស៊ីគ្រលំ ឬសមគំនិតគ្នាជាមួយនឹងស្ថាប័នរដ្ឋ នៅតែបន្តកេងប្រវ័ញ្ចលើអ្នកត្រូវបានគេបណ្តេញចេញតាមរយៈពលកម្មកុមារ ការផ្តល់ប្រាក់ឈ្នួលទាប និងការបដិសេធផ្តល់សំណងសមរម្យ។

ថ្វីបើមានការធានានៅក្នុងច្បាប់ជាតិ និងអន្តរជាតិ សហគមន៍នៅតែបន្តទទួលរងការរំលោភយកដីរបស់ពួកគាត់ដោយខុសច្បាប់ ដើម្បីផ្ទេរទៅឱ្យក្រុមហ៊ុនឯកជនធ្វើកសិកម្មបែបពាណិជ្ជកម្ម (ដូចជា ចម្ការអំពៅ និងកៅស៊ូ ជាដើម) និងគម្រោងរុករករ៉ែ និងថាមពល ដូចជាទំនប់វារីអគ្គិសនី។ សកម្មភាពធុរកិច្ចទាំងនោះបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមានលំនៅដ្ឋានសមរម្យ ការទទួលបានស្បៀងអាហារ និងទឹកឱ្យបានគ្រប់គ្រាន់ ព្រមទាំង

មានផលប៉ះពាល់រយៈពេលវែងទៅលើបរិស្ថាន និងសេដ្ឋកិច្ចផងដែរ។ ករណីសិក្សា[1]ខាងក្រោមនេះបង្ហាញពីការរំលោភបំពានលើសិទ្ធិដីធ្លី ៖

**ករណីសិក្សា ៖ ក្រុមហ៊ុនស្ករ មិទ្រ ផុល នៅខេត្តឧត្តរមានជ័យ**

ក្រុមហ៊ុនស្ករអង្គរ ក្រុមហ៊ុនស្ករអំពៅទន្លេ និងក្រុមហ៊ុនអំពៅ និងស្ករ វ៉ៃឡេ គឺសុទ្ធតែជាក្រុមហ៊ុនបុត្រសម្ពន្ធរបស់ក្រុមហ៊ុនស្ករ មិទ្រ ផុល ដែលជាក្រុមហ៊ុនសាជីវកម្មថៃ ដែលជាក្រុមហ៊ុនផលិតស្ករ និងថាមពលជីវសាស្ត្រធំបំផុតនៅអាស៊ី។ នៅក្នុងឆ្នាំ២០១៤ ក្រុមហ៊ុនមិទ្រ ផុល ត្រូវបានបង្ហាញជាសាធារណៈថា ជាអ្នកផ្គត់ផ្គង់ស្ករឱ្យក្រុមហ៊ុនកូកា កូឡា (សហរដ្ឋអាមេរិក) ធំទីបី។ នៅក្នុងឆ្នាំ២០០៨ ក្រុមហ៊ុនទាំងនេះ ទទួលបានសម្បទានដីសេដ្ឋកិច្ចនៅស្រុកសំរោង និងចុងកាល់នៅខេត្តឧត្តរមានជ័យ។

ច្បាប់ភូមិបាលកម្ពុជាបានចែងពីការហាមក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចលើសពី ១០.០០០ ហិចតា ហើយច្បាប់នេះក៏ហាមបុគ្គល ឬស្ថាប័នតែមួយមិនឱ្យកាន់កាប់សម្បទានដីសេដ្ឋកិច្ចសរុបមិនលើសពី ១០.០០០ ហិចតាដែរ។ សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទាំងបីនេះមានចំនួន ១៩.៧០០ ហិចតា ទំហំជិតពីរដងនៃទំហំដែលច្បាប់បានកំណត់។ ពុំមានការពិភាក្សាជាមួយនឹងអ្នកភូមិ មុននឹងយកដីទាំងនេះទៅផ្តល់សម្បទានដីសេដ្ឋកិច្ចឱ្យក្រុមហ៊ុន ហើយអ្នកភូមិបានដឹងអំពីបញ្ហានេះនៅខែវិច្ឆិកា ឆ្នាំ២០០៧ នៅពេលដែលអាជ្ញាធរខេត្តបានចាប់ផ្តើមបោះបង្គោលកំណត់ចំណាំនៅតំបន់នោះ។

ចុងក្រោយ សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមិទ្រ ផុល បានប៉ះពាល់ដល់ភូមិចំនួន ២៦ និង ២.០៧៣ គ្រួសារ។ ដីលំនៅដ្ឋាន និងដីចម្ការចំនួន ៩.៤៣០ ហិចតាត្រូវបានដកហូត ហើយផ្ទះរាប់រយខ្នង (និងទ្រព្យសម្បត្តិ) ត្រូវបានដុតបំផ្លាញនៅក្នុងដំណើរការនេះ។ ផ្លូវទៅកាន់ប្រាសាទ និងតំបន់បុរាណផ្សេងៗទៀតក៏ត្រូវបាត់បង់ផងដែរ។ ផ្លូវទៅកាន់វាលស្រែកសិកម្ម និងចម្ការត្រូវបានរឹតត្បិតចាប់ពីខែកុម្ភៈ ឆ្នាំ២០០៨ ហើយការដេញចេញដោយបង្ខំបានចាប់ផ្តើមក្នុងខែមេសានៅក្នុងឆ្នាំដដែលនេះ។ កាលពីខែមេសា ឆ្នាំ២០០៨ បុគ្គលិកក្រុមហ៊ុនស្ករអង្គរ បានបំផ្លិចបំផ្លាញផ្ទះរបស់អ្នកភូមិចំនួន ១៥៤ ខ្នង នៅភូមិអូរបាត់មាន់។ ក្នុងខែតុលា ឆ្នាំ២០០៩ ផ្ទះចំនួន ១០០ ខ្នងរបស់អ្នកភូមិដដែលនេះត្រូវបានបំផ្លិចបំផ្លាញថែមទៀត។ ជារួមទាំងពីរករណីខាងលើនេះបង្កឱ្យមានការខូចខាតផ្ទះ និងទ្រព្យសម្បត្តិភូមិទាំងមូល (ចំនួន ២១៤ គ្រួសារ)។ ការបណ្តេញ និងការបំផ្លិចបំផ្លាញផ្ទះ និងទ្រព្យសម្បត្តិរបស់អ្នកភូមិភាគច្រើនធ្វើឡើងដោយទាហានកងពលតូចលេខ៤២ ដែលឧបត្ថម្ភជាផ្លូវការដោយក្រុមហ៊ុនកាស៊ីណូអូរស្មាច់របស់លោក លី យ៉ុងផាត់។

ដីសម្បទានសេដ្ឋកិច្ចទំហំត្រឹមតែ ១,១% (ស្មើនឹង ២១៩ ហិចតា) នៃចំនួនសរុបបានដាំកូនដើមអំពៅ ហើយក្រុមហ៊ុនបានចុះកិច្ចសន្យាពាក់ព័ន្ធនឹងការកាប់ឆ្ការឈើជាមួយនឹងក្រុមទីបី។ ចុងក្រោយ ការធ្វើយុទ្ធនាការជាបន្តបន្ទាប់អស់ រយៈពេលជាច្រើនឆ្នាំរបស់អ្នកភូមិដែលរងផលប៉ះពាល់ ដើម្បីទាមទារដីរបស់ខ្លួនត្រឡប់

[1] សម្រាប់ព័ត៌មានបន្ថែម៖ អង្គការអុកហ្វាម (Oxfam) និងអង្គការអាក់សិនអេត, "កម្ពុជា ៖ រសជាតិជូរចត់នៃស្ករស ការផ្លាស់ទីជម្រក និងការដកហូតដីធ្លីនៅក្នុងខេត្តឧត្តរមានជ័យ" (ឆ្នាំ២០១៥) តាមរយៈ http://bit.ly/1lyeo96

មកវិញ និងរួមទាំងការរិះគន់ជាច្រើនជុំវិញការរំលោភបំពានសិទ្ធិមនុស្សនៅលើដីសម្បទានសេដ្ឋកិច្ចនេះ ក្រុមហ៊ុនមិត្រ ផុល បានដកខ្លួនចេញនៅក្នុងឆ្នាំ២០១៥។ ទោះជាយ៉ាងនេះក្តី ដីទាំងនេះមិនទាន់ត្រូវបានប្រគល់ត្រឡប់ទៅឱ្យម្ចាស់ដើមវិញនៅឡើយទេ ហើយក៏មិនទាន់មានការព្រមព្រៀងផ្តល់សំណងដល់អ្នកភូមិរងផលប៉ះពាល់ក្រោយហេតុការណ៍ទាំងអស់នេះនៅឡើយដែរ។



ការប្រមូលផលអំពៅនៅលើដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមិត្រ ផុល

ប្រភព ៖ អាក់សិនអេត

នីតិរដ្ឋដ៏ទន់ខ្សោយនៅក្នុងប្រទេសកម្ពុជា គឺពិតជាកត្តាមួយដែលធ្វើឱ្យក្រុមហ៊ុនឯកជនជាច្រើនរំលោភសិទ្ធិមនុស្សយ៉ាងងាយនៅក្នុងប្រតិបត្តិធុរកិច្ចរបស់ខ្លួន។

ជនរងគ្រោះ ដែលរងការរំលោភបំពានសិទ្ធិមនុស្សដោយសារតែធុរកិច្ចនេះ ភាគច្រើនជាអ្នកងាយរងគ្រោះបំផុតនៅក្នុងសង្គម ដែលពួកគាត់មានធនធានតិចតួចក្នុងការងើបឡើងតស៊ូប្រឆាំងនឹងការរំលោភបំពានទាំងនេះ ដូចជាអ្នកក្រ អ្នកបានទទួលប្រយោជន៍តិចតួច ស្ត្រី សហគមន៍ជនជាតិដើមភាគតិច ហើយជាទូទៅគឺអ្នកដែលមិនសូវបានដឹងអំពីសិទ្ធិរបស់ខ្លួន និងច្បាប់។

## ១.៣.២ សិទ្ធិ និងការទទួលខុសត្រូវ

ដូចពិភាក្សាខាងលើ សិទ្ធិមនុស្សមានជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបុគ្គលម្នាក់ៗ។ មានសិទ្ធិមួយចំនួនដែលជាប់ពាក់ព័ន្ធនឹងក្រុមសមូហភាព។ ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា ជនជាតិដើមភាគតិចមានសិទ្ធិធ្វើជាម្ចាស់ដីសមូហភាព។ នៅក្នុងកម្រិតអន្តរជាតិ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចឆ្នាំ២០០៧ បានចែងយ៉ាងច្បាស់លាស់អំពីសិទ្ធិមួយចំនួនដែលជនជាតិដើមភាគតិចត្រូវទទួលបាន រួមទាំងសិទ្ធិបុគ្គល និងសិទ្ធិជាសមូហភាព។ ក៏ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង សិទ្ធិបុគ្គល និងសិទ្ធិជាសមូហភាពជារឿយៗ មិនត្រូវបានគេគោរពពេញលេញនោះទេ។

បុគ្គលគ្រប់រូបរាប់ទាំងបុគ្គលឯកជន ឬជាក្រុម ក៏មានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិរបស់អ្នកដទៃដែរ ដូចដែលមានចែងនៅក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។

នៅពេលផ្តោតទៅលើធុរកិច្ចនិងសិទ្ធិមនុស្ស ការទទួលខុសត្រូវត្រូវមានចំណែករបស់រដ្ឋ និងរបស់ធុរកិច្ច។ រដ្ឋ គឺជារដ្ឋាភិបាល ស្ថាប័នរដ្ឋ និងបុគ្គលទាំងឡាយដែលធ្វើការឱ្យរដ្ឋាភិបាល និងស្ថាប័នសាធារណៈ ត្រូវមានការទទួលខុសត្រូវក្នុងការធានាថាសិទ្ធិទាំងឡាយរបស់ពលរដ្ឋត្រូវបានគោរព ការពារ និងបំពេញ។ នេះគឺជាចំណែកជាមូលដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ទោះបីជាភារកិច្ចចម្បងក្នុងការការពារនិងបំពេញសិទ្ធិមនុស្សជាភារកិច្ចរបស់រដ្ឋក៏ដោយ ក៏ធុរកិច្ចកាន់តែច្រើនឡើងកំពុងទទួលស្គាល់ការទទួលខុសត្រូវទាំងនេះក្នុងការការពារសិទ្ធិមនុស្ស។ លើសពីនេះទៀត ធុរកិច្ចត្រូវបានគេតម្រូវឱ្យអនុលោមតាមច្បាប់ជាតិ ហេតុដូច្នេះហើយរាល់លិខិតុបករណ៍ច្បាប់អន្តរជាតិទាំងឡាយដែលត្រូវបានផ្តល់សច្ចាប័នគឺត្រូវអនុលោមតាមច្បាប់ជាតិ។

នៅពេលដែលរដ្ឋ និងធុរកិច្ចខកខានក្នុងការការពារសិទ្ធិមនុស្សនោះ តួអង្គផ្សេងទៀតអាចជួយលើកកម្ពស់ការការពារសិទ្ធិមនុស្សក្នុងទិដ្ឋភាពជាក់ស្តែងដោយរួមមានទាំងអង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងមេដឹកនាំសាសនា។ បន្ថែមពីលើនេះទៀត សហគមន៍ និងកម្មករ ត្រូវតែដឹង និងតស៊ូដើម្បីសិទ្ធិរបស់ខ្លួនដែរ។

## ១.៣.៣ ធុរកិច្ចនិងសិទ្ធិមនុស្ស ធៀបនឹងការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម




កាលពីមុន ធុរកិច្ចបានព្យាយាមដោះស្រាយបញ្ហាសង្គមតាមរយៈកម្មវិធីទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម។ ការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម ជាសកម្មភាពស្ម័គ្រចិត្តដែលក្រុមហ៊ុនរៀបចំឡើងដើម្បីប្រតិបត្តិការក្នុងលក្ខណៈដែលមាននិរន្តរភាពផ្នែកសង្គម និងបរិស្ថាន។ ឧទាហរណ៍ ក្រុមហ៊ុនអ៊ីហ្ស៊ីខម ដែលជាក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធើណិតមួយនៅកម្ពុជា បានបញ្ចូលការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គមទៅក្នុងគំរូធុរកិច្ចរបស់ខ្លួន ដែលថែមទាំងជួលអ្នកគ្រប់គ្រងម្នាក់ឱ្យធ្វើការលើការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គមផងដែរ (ជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដ៏កម្រនៅកម្ពុជាដែលធ្វើដូច្នេះ)។ ក្រុមហ៊ុនអ៊ីហ្ស៊ីខម អះអាងថាខ្លួននឹងប្តេជ្ញាប្រើប្រាស់ថាមពលបច្ចេកវិទ្យាដើម្បីជួយដល់ការរីកលូតលាស់របស់សហគមន៍ និងជួយឱ្យប្រជាជនសម្រេចបាននូវសក្តានុភាពរបស់ពួកគេ។ ជាផ្នែកមួយនៃការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គមរបស់ខ្លួន ក្រុមហ៊ុនអ៊ីហ្ស៊ីខមផ្តល់សេវាអ៊ិនធើណិតដោយឥតគិតថ្លៃដល់ថ្នាក់រៀនកុំ

ព្យូទ័ររបស់អង្គការមិត្តសំឡាញ់អន្តរជាតិ ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយធ្វើការជាមួយកុមារដែលមិនសូវមានឱកាស។ ទោះជាយ៉ាងណាក្តី ប្រការគួរឱ្យកត់សម្គាល់គឺថា ជារឿយៗនៅពេលក្រុមហ៊ុនក្នុងស្រុកកំពុងតែលើកកម្ពស់ពីគោលនយោបាយការទទួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គមរបស់ពួកគេ ស្របពេលជាមួយគ្នាក្រុមហ៊ុនទាំងនេះក៏កំពុងប្រព្រឹត្តការរំលោភបំពានសិទ្ធិមនុស្សនៅពីខាងក្រោយផងដែរ។

ផ្ទុយទៅវិញ ការគោរពសិទ្ធិមនុស្សនៅក្នុងធុរកិច្ច មិនមែនជាការស្ម័គ្រចិត្តទេ ប៉ុន្តែចាំបាច់ត្រូវអនុវត្តតាមលក្ខណៈជាសកលនៃសិទ្ធិមនុស្ស ហើយតម្រូវឱ្យក្រុមហ៊ុនគោរពសិទ្ធិមនុស្សទាំងអស់នៅរាល់ប្រតិបត្តិការរបស់ខ្លួន។ ក្របខណ្ឌសិទ្ធិមនុស្ស ផ្តល់នូវវិធីសាស្ត្រមួយដែលត្រូវបានទទួលស្គាល់ជាសកល និងផ្តោតទៅលើមនុស្សចំពោះផលប៉ះពាល់របស់ក្រុមហ៊ុនទៅលើសង្គម និងបរិស្ថាន។

# ២. គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស

## ២.១ តើអ្វីជាគោលការណ៍ណែនាំ?

គោលការណ៍ណែនាំ គឺជាបណ្តុំគោលការណ៍ចំនួន៣១ ដើម្បីកំណត់ និងបង្ហាញណែនាំផ្លូវអំពីវិធីដែលរដ្ឋ និងធុរកិច្ចអាចការពារ និងលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅក្នុងប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃ។ ដោយផ្អែកទៅលើកិច្ចប្រឹងប្រែងចំនួន៦ឆ្នាំ ដោយអតីតតំណាងពិសេសរបស់អង្គការសហប្រជាជាតិគឺលោក ចន រ៉ូហ្គី គោលការណ៍ណែនាំនេះ ត្រូវបានបង្កើតឡើងដើម្បីដាក់ឱ្យប្រតិបត្តិការនូវក្របខណ្ឌ "ការការពារ ការគោរព និងដំណោះស្រាយ" ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងឆ្នាំ២០០៨។ ក្របខណ្ឌនេះមានសសរស្តម្ភចំនួន៣ ៖

| | | |
|---|---|---|
| **ការការពារ** | **ការគោរព** | **ដំណោះស្រាយ** |
| **កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ** ប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្ស | **ទំនួលខុសត្រូវរបស់អាជីវកម្មក្នុងការគោរព** សិទ្ធិមនុស្ស | **តម្រូវការក្នុងការទទួលបានដំណោះស្រាយ** សម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានពាក់ព័ន្ធនឹងធុរកិច្ច |

**សសរស្តម្ភទី១ ៖ កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ** ប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្សដោយភាគីទីបី តាមរយៈគោលនយោបាយ បទប្បញ្ញត្តិ និងការជម្រះសេចក្តីជាក់លាក់និងសមស្រប។

**សសរស្តម្ភទី២ ៖ ទំនួលខុសត្រូវរបស់អាជីវកម្មក្នុងការគោរព** សិទ្ធិមនុស្សដែលមានន័យថាធុរកិច្ចទាំងអស់ ទាំងតូចទាំងធំ ត្រូវគេរំពឹងថាត្រូវជៀសវាងការរំលោភបំពានសិទ្ធិមនុស្សរបស់អ្នកដទៃ និងត្រូវដោះស្រាយការប៉ះពាល់សិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលពួកគេមានការពាក់ព័ន្ធ។

**សសរស្តម្ភទី៣ ៖ ការទទួលបានដំណោះស្រាយ** ដែលទាមទារឱ្យរដ្ឋ និងធុរកិច្ច ធានាឱ្យមានការជនរងគ្រោះដោយសារការបំពានសិទ្ធិមនុស្សដោយសារធុរកិច្ច កាន់តែទទួលបានដំណោះស្រាយដែលមានប្រសិទ្ធភាព ទាំងផ្នែកតុលាការ និងក្រៅប្រព័ន្ធតុលាការ។

សម្រាប់សសរស្តម្ភនីមួយៗ គោលការណ៍ណែនាំនេះផ្តល់នូវការណែនាំជាក់លាក់ដល់រដ្ឋ និងធុរកិច្ចក្នុងការអនុវត្តក្របខណ្ឌនេះ។ វាជាការសំខាន់ក្នុងការកត់សម្គាល់នៅទីនេះដែរថា គោលការណ៍ណែនាំនោះមិនបាន

ចងកាតព្វកិច្ចតាមផ្លូវច្បាប់ទេ តែគ្រាន់តែលើកទឹកចិត្តជាជាងដាក់ជាកាតព្វកិច្ចដល់រដ្ឋ និងវិស័យធុរកិច្ចក្នុងការអនុវត្តក្របខណ្ឌ "ការការពារ ការគោរព និងដំណោះស្រាយ"។ ទោះបីជាមានកំហិតបែបនេះក៏ដោយ ក៏ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆ័ន្ទទៅលើគោលការណ៍ណែនាំនេះនៅក្នុងខែមិថុនា ឆ្នាំ២០១១ ដោយបានធ្វើឱ្យគោលការណ៍ណែនាំនេះក្លាយជាស្តង់ដារសាកលសម្រាប់អនុវត្ត ដែលឥឡូវនេះត្រូវបានរំពឹងថាគ្រប់រដ្ឋ និងធុរកិច្ចអនុវត្តតាមចំពោះធុរកិច្ចនិងសិទ្ធិមនុស្ស។ បន្ថែមពីលើនេះ គោលការណ៍ណែនាំនេះ មានបញ្ចូលចំណុចដែលមានគ្របដណ្តប់ក្នុងច្បាប់អន្តរជាតិ។ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ ថ្មីៗនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានបោះឆ្នោតបង្កើតក្រុមការងារមួយ ដើម្បីតាក់តែងលិខិតុបករណ៍អន្តរជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ដែលអាចចងជាកាតព្វកិច្ចតាមផ្លូវច្បាប់ ដូច្នេះវាអាចទៅរួចដែលថាការវិវឌ្ឍនៅពេលអនាគតអាចនឹងប្រែក្លាយការទទួលខុសត្រូវទាំងនេះឱ្យទៅជាកាព្វកិច្ចតាមផ្លូវច្បាប់ដែលតម្រូវឱ្យរដ្ឋ និងធុរកិច្ចគោរពតាម។




ប្រភព ៖ ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

## ២.២ ភាតព្វកិច្ចរបស់រដ្ឋក្នុងការការពារសិទ្ធិមនុស្ស



តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងទប់ស្កាត់មិនឱ្យតួអង្គឯកជន និងមិនមែនរដ្ឋប្រព្រឹត្តបំពានសិទ្ធិរបស់អ្នកដទៃ។

ដូចបានពិភាក្សាខាងលើរួចមកហើយ បុគ្គលគ្រប់រូបមានកាតព្វកិច្ចក្នុងការគោរពសិទ្ធិរបស់អ្នកដទៃ។ ក៏ប៉ុន្តែ អ្នកមានកាតព្វកិច្ចចម្បងក្នុងបញ្ហាសិទ្ធិមនុស្សនេះគឺរដ្ឋ។ រដ្ឋមានកាតព្វកិច្ចក្នុងការអនុម័ត និងអនុវត្តច្បាប់

បទប្បញ្ញត្តិ និងគោលនយោបាយ ដោយមានគោលបំណងការពារសិទ្ធិរបស់មនុស្ស។ ក្នុងករណីនៅកន្លែងដែលសកម្មភាពរបស់បុគ្គលឯកជន ឬក្រុមហ៊ុនឯកជន រំលោភសិទ្ធិអ្នកដទៃនោះ វាជាកាតព្វកិច្ចរបស់រដ្ឋក្នុងការធានាថា សំណងត្រូវបានផ្តល់ជូនដល់អ្នកត្រូវទទួលរងការរំលោភបំពានសិទ្ធិនេះ។ ម្យ៉ាងវិញទៀត នៅពេលដែលការរំលោភបំពានសិទ្ធិរបស់ពលរដ្ឋ អាចត្រូវបង្កឡើងពីសំណាក់បុគ្គល ឬក្រុមហ៊ុនឯកជននោះ រដ្ឋមានការទទួលខុសត្រូវក្នុងការការពារសិទ្ធិទាំងនោះ ហើយរដ្ឋក៏ត្រូវមានកាតព្វកិច្ចក្នុងការបញ្ចប់ការខូចខាតដល់ពលរដ្ឋ និងក្នុងការផ្តល់សំណង ដូចជាសំណងសម្រាប់ពលរដ្ឋដែលទទួលរងការប៉ះពាល់ទៅលើសិទ្ធិ ឬការកាត់ទោសព្រហ្មទណ្ឌទៅលើបុគ្គល ឬក្រុមហ៊ុនឯកជនដែលជាជនល្មើស។

ឧទាហរណ៍ល្អមួយ ដែលបញ្ជាក់ច្បាស់អំពីកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារគឺ ក្រុមហ៊ុនស្ករមួយដែលផ្តល់ការងារដល់កម្មករធ្វើការនៅក្នុងចម្ការរបស់ខ្លួន។ ក្រុមហ៊ុនស្ករគឺជាធុរកិច្ចឯកជន ហើយមិនមែនជាផ្នែកណាមួយរបស់រដ្ឋាភិបាលទេ។ ពលកម្មលើកុមារគឺជាការរំលោភសិទ្ធិមនុស្សជាមូលដ្ឋាន និងត្រូវបានគេបង្ហាញថាអាចធ្វើឱ្យប៉ះពាល់ដល់ការរីកលូតលាស់របស់កុមារ។ ជាងនេះទៅទៀត យោងតាមច្បាប់ជាតិ អាយុអប្បបរមាដែលអាចធ្វើការបានគឺចាប់ពី១៥ ឆ្នាំ។ ស្របតាមកាតព្វកិច្ចក្នុងការការពារ រដ្ឋាភិបាលត្រូវធានាថាបុគ្គល និងក្រុមហ៊ុនឯកជនដែលគ្រប់គ្រងចម្ការទាំងនោះ មិនមានប្រើប្រាស់ពលកម្មកុមារនៅក្នុងចម្ការរបស់ខ្លួនជាដាច់ខាតដែលរដ្ឋអាចបង្កើតច្បាប់ ឬប្តឹងចោទប្រកាន់លើម្ចាស់ចម្ការណាដែលបានប្រើប្រាស់ពលកម្មកុមារត្រូវបញ្ជូនទៅតុលាការ។ រដ្ឋក៏ត្រូវធានាដែរថា កុមារដែលរងគ្រោះដោយសារតែការប្រព្រឹត្តរបស់ក្រុមហ៊ុនកើតចេញពីការងារនៅចម្ការ ហើយដែលសិទ្ធិរបស់កុមារទាំងនោះត្រូវបានបំពាន អាចទទួលបានសំណងសមស្រប។ នៅក្នុងកាលៈទេសៈបែបនេះ តុលាការអាចបង្គាប់ឱ្យម្ចាស់ចម្ការចេញថ្លៃសំណងនៃការខូចខាត តែក៏អាស្រ័យតាមកាលៈទេសៈនៃករណីជាក់លាក់ដែរ ដែលតុលាការត្រូវផ្តន្ទាទោសម្ចាស់ចម្ការថែមទៀត ប្រសិនបើតុលាការរកឃើញថា ម្ចាស់ចម្ការទាំងនោះមានពិរុទ្ធចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ។

ក្នុងការអនុវត្តនៅប្រទេសកម្ពុជា មានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ។ ឧបសគ្គចម្បងបំផុតគឺកង្វះការពង្រឹង និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលជាប់ទាក់ទិនទៅនឹងអំពើពុករលួយរីករាលដាលក្នុងចំណោមអ្នកមានអំណាច ដែលបណ្តោយឱ្យធុរកិច្ចប្រព្រឹត្តអំពើរំលោភបំពានសិទ្ធិមនុស្ស ដោយមិនទទួលរងនូវទណ្ឌកម្ម។ យោងតាមអង្គការគ្លូបល់វីតនេស (Global Witness) ២០% នៃដីទាំងអស់ដែលត្រូវបានបែងចែកតាមរយៈសម្បទានដីសេដ្ឋកិច្ច ត្រូវបានកាន់កាប់ដោយសមាជិកព្រឹទ្ធសភាចំនួន៥ រូបនៃគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។ ឧទាហរណ៍ ក្រុមហ៊ុនភាពីម៉ិច ដែលជាក្រុមហ៊ុនដ៏មានឥទ្ធិពលបំផុតមួយក្នុងប្រទេសកម្ពុជា មានម្ចាស់រួមគ្នាដោយសមាជិកព្រឹទ្ធសភា ឡៅ ម៉េងឃីន និងត្រូវបានគេប៉ាន់ប្រមាណថាគ្រប់គ្រងលើដីចំនួន៧% នៃផ្ទៃដីប្រទេសកម្ពុជា។ សមាជិកព្រឹទ្ធសភារូបនេះ គឺជានាយកក្រុមហ៊ុនស៊ូកាគូ ដែលជាក្រុមហ៊ុនទទួលខុសត្រូវក្នុងការបណ្តេញប្រជាជនចំនួនប្រហែល ៣.០០០ នាក់ចេញដោយបង្ខំពីតំបន់បឹងកក់។ ទំនាស់ផលប្រយោជន៍បែបនេះ ជាការពន្យល់ថាហេតុអ្វីបានជារដ្ឋាភិបាលច្រើនតែបណ្តោយឱ្យក្រុមហ៊ុនរួចខ្លួនពីការរំលោភបំពានសិទ្ធិមនុស្ស។ បន្ថែមពីលើនេះ មានការខ្វះខាតការយល់

ដឹងជាទូទៅក្នុងចំណោមមន្ត្រីរដ្ឋាភិបាលអំពីរបៀបក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារ និងធានាថាធុរកិច្ចគោរពសិទ្ធិមនុស្ស។ គោលការណ៍ណែនាំទាំងនេះ ផ្តល់នូវដំណោះស្រាយមួយសម្រាប់បញ្ហានេះ ដោយសារតែវាផ្តល់នូវអនុសាសន៍ជាក់ស្តែងមួយចំនួនសម្រាប់រដ្ឋាភិបាលក្នុងការអនុវត្តតាមដើម្បីធានាថាពួកគេបំពេញតួនាទីរបស់ខ្លួនបាន។ ដ្យាក្រាមខាងក្រោមនេះ បង្ហាញអំពីសំណើជាក់ស្តែងមួយចំនួន សម្រាប់សកម្មភាពដែលរដ្ឋាភិបាលអាចចាប់យកក្នុងការអនុវត្តគោលការណ៍ណែនាំ ៖




## ២.៣ ទំនួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស

ប្រហែលជាតួអង្គសំខាន់បំផុតដែលត្រូវតែមានការពាក់ព័ន្ធគឺធុរកិច្ច ប្រសិនបើគោលការណ៍ណែនាំទាំងនេះត្រូវអនុវត្តឱ្យបានជោគជ័យនោះ។ សូម្បីតែមានសកម្មភាពខ្លាំងក្លាពីរដ្ឋក្រោមជាតុ "ការការពារ" តាមគោលការណ៍ណែនាំទាំងនេះក៏ដោយ ក៏ការអនុវត្តច្បាស់ណាស់ថានឹងមិនមានប្រសិទ្ធភាពទេ ប្រសិនបើធុរកិច្ច មិនបានបំពេញតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការគោរពសិទ្ធិមនុស្ស និងធានាថាពួកគេមិនបង្កផលប៉ះពាល់នៅពេលបំពេញប្រតិបត្តិការរបស់ខ្លួន។

វាទំនងជាមានការប្រឈមខ្លាំងសម្រាប់ធុរកិច្ចក្នុងការដាក់ចេញនូវប្រតិបត្តិការជាការអនុវត្តឱ្យបានល្អបំផុតដែលមានចែងនៅក្នុងគោលការណ៍ណែនាំ ហេតុដូច្នេះ វាជាការសំខាន់ណាស់ដែលយើងត្រូវចំណាយ

ពេលវេលាក្នុងការទទួលស្គាល់ឧបសគ្គទាំងនេះ។ វាក៏មានសារៈសំខាន់ផងដែរក្នុងការទទួលស្គាល់ថា ទោះបីជាគោលការណ៍ណែនាំទាំងនេះ ត្រូវបានគេតាក់តែងឡើងជា "គោលការណ៍មួយតម្រូវឱ្យអនុវត្តបានគ្រប់គ្នា" ដែលឱ្យអាចអនុវត្តបានសម្រាប់ធុរកិច្ចគ្រប់ទំហំ និងសម្រាប់អ្នកប្រតិបត្តិនៅក្នុងឧស្សាហកម្មផ្សេងៗគ្នានោះ បញ្ហាប្រឈមជាក់លាក់មួយចំនួន ទំនងជាអាចមានភាពខ្លាំងក្លាជាងនេះ នៅក្នុងធុរកិច្ចមួយចំនួន ដូចជាធុរកិច្ចខ្នាតតូចជាដើម។ ខាងក្រោមនេះជាបញ្ហាប្រឈមសំខាន់ៗបំផុតមួយចំនួនដែលធុរកិច្ចជួបប្រទះ ៖

- ក្រុមហ៊ុនតូចៗ អាចយល់ថាខ្លួននូវខ្វះខាតធនធាននានា ដែលអាចជួយឱ្យពួកគេអនុវត្តគោលការណ៍ណែនាំទាំងនេះឱ្យបានជោគជ័យ
- ធុរកិច្ចអាចចោទសួរថាតើការអនុវត្តគោលការណ៍ណែនាំនឹងផ្តល់ឱ្យពួកគេនូវផលប្រយោជន៍ដែរឬទេ
- ធុរកិច្ចអាចមានអារម្មណ៍ថាហានិភ័យដ៏ធំទាក់ទងនឹងក្តីក្តាំដោយសារតែបញ្ហាសិទ្ធិមនុស្សគឺជាហានិភ័យដែលពួកគេមានឆន្ទៈនឹងទទួលយក
- នៅកន្លែងដែលរដ្ឋមិនបានបំពេញតួនាទីក្នុង "ការការពារ" ទេ ធុរកិច្ចអាចចោទសួរថាហេតុអ្វីបានជាពួកគេត្រូវបំពេញតួនាទីក្នុង "ការគោរព"
- ធុរកិច្ចអាចមានការលំបាកក្នុងការបង្កើតនូវយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយសម្រាប់ការអនុវត្តគោលការណ៍ណែនាំទាំងនេះ។

ច្បាស់ណាស់ថា បញ្ហាប្រឈមមួយចំនួនក្នុងចំណោមបញ្ហាប្រឈមខាងលើ មានការពាក់ព័ន្ធនឹងភាគីផ្សេងទៀតក្រៅពីធុរកិច្ច ប៉ុន្តែមនុស្សជាច្រើនផ្តោតទៅលើវិធីដែលធុរកិច្ចអាចនឹងរំខានដោយសារតែសេចក្តីលម្អិតនៃគោលការណ៍ណែនាំ។ ជាធម្មតា នៅពេលដែលគេមើលឃើញថាវាកាន់តែមានភាពស្មុគស្មាញក្នុងការអនុវត្តគោលការណ៍នេះ ធុរកិច្ចកាន់តែមិនចង់បញ្ចូលគោលការណ៍ណែនាំទាំងនេះ ចូលទៅក្នុងការអនុវត្តការងាររបស់ខ្លួន។ ដោយចងចាំក្នុងចិត្តអំពីប្រការនេះ គំរូប្រាំមួយជំហានយ៉ាងងាយស្រួល ដែលគេផ្តល់យោបល់ឱ្យធុរកិច្ចអនុវត្តតាមនៅពេលអនុវត្តគោលការណ៍ណែនាំទាំងនោះ។[2] ដំណើរការទាំងប្រាំមួយជំហាននេះ មានដូចខាងក្រោម ៖

[2] អង្គការ SAI & ICCO, 'គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ៖ យុទ្ធសាស្ត្រ៦ចំណុចក្នុងការអនុវត្តខ្សែសង្វាក់ផ្គត់ផ្គង់' ស្វែងរកបានតាមរយៈ http://bit.ly/297leco

ជំហាន 1 • **ប្តេជ្ញាចិត្ត** ចំពោះគោលនយោបាយសិទ្ធិមនុស្ស

ជំហាន 2 • **ប៉ាន់ប្រមាណ** ការប៉ះពាល់សិទ្ធិមនុស្ស

ជំហាន 3 • **បញ្ចូល** គោលនយោបាយ នីតិវិធី និងការទទួលខុសត្រូវអំពីសិទ្ធិមនុស្ស

ជំហាន 4 • **តាមដាន** ការអនុវត្តសិទ្ធិមនុស្ស

ជំហាន 5 • **ប្រាស្រ័យទាក់ទង** អំពីការប៉ះពាល់សិទ្ធិមនុស្ស

ជំហាន 6 • **ផ្តល់ដំណោះស្រាយ** ចំពោះការប៉ះពាល់សិទ្ធិមនុស្ស

ករណីសិក្សាខាងក្រោមនេះ ផ្តល់នូវឧទាហរណ៍នៃធុរកិច្ចប្រតិបត្តិការក្នុងប្រទេសកម្ពុជា ដែលបានដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សដែលពួកគេបានបង្ក ឬរួមចំណែកប្រកបដោយជោគជ័យ ព្រមទាំងកិច្ចប្រឹងប្រែងដែលក្រុមហ៊ុនបានធ្វើដើម្បីជួសជុល។ ករណីសិក្សានេះពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងបានផ្តល់ជាឧទាហរណ៍ដ៏មានប្រយោជន៍មួយអំពីរបៀបក្នុងការអនុវត្តតាមគោលបំណងនៃគោលការណ៍ណែនាំទាំងនេះក្នុងការអនុវត្តជាក់ស្តែង។

**ករណីសិក្សា ៖ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឈ្មោះ ហ្វូង អាញ ហ្គៃឡៃ (HAGL) នៅក្នុងខេត្តរតនគីរី [3]**

កាលពីខែកុម្ភៈ ឆ្នាំ២០១៤ អ្នកភូមិជនជាតិដើមភាគតិចចំនួន ១៧ ភូមិដែលមានទីតាំងស្ថិតក្នុងស្រុកអណ្តូងមាស និងស្រុកអូរជុំក្នុងខេត្តរតនគិរី បានដាក់ពាក្យបណ្តឹងទៅស្ថាប័នផ្តល់ប្រាក់កម្ចីទៅឱ្យវិស័យឯកជនរបស់ធនាគារពិភពលោក ដែលហៅថាសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ("IFC") ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានទៅឱ្យក្រុមហ៊ុនកៅស៊ូវៀតណាមឈ្មោះថា Hoang Anh Gia Lai (ក្រុមហ៊ុន HAGL) និងសាខារបស់ក្រុមហ៊ុននេះ ដែលបានប្រព្រឹត្តការរំលោភបំពានជាច្រើន។ នៅក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមផ្តល់សម្បទានដីសេដ្ឋកិច្ចរាប់ពាន់ហិចតាទៅឱ្យក្រុមហ៊ុន HAGL នៅក្នុងតំបន់នោះសម្រាប់ដំណាំកៅស៊ូ។

អ្នកភូមិដែលរងគ្រោះ និងក្រុមហ៊ុន HAGL មានទំនាស់នឹងគ្នាអស់ជាច្រើនឆ្នាំមកហើយ ដោយសារការចោទប្រកាន់ថាក្រុមហ៊ុន HAGL បានទន្ទ្រានយកដីរបស់អ្នកភូមិ បន្ថែមពីលើការបំពានសិទ្ធិមនុស្សផ្សេងទៀត រួមទាំងការកាប់បំផ្លាញព្រៃឈើយ៉ាងច្រើន ការបំពុលទឹកអូរដោយការប្រើថ្នាំគីមីនៅក្នុងការដាំដុះ និងការបំពានផ្លូវភេទ។

បន្ទាប់ពីមានការសម្របសម្រួលរវាងក្រុមហ៊ុន HAGL និងអ្នកភូមិដែលទទួលរងគ្រោះដែលរៀបចំដោយការិយាល័យអង្កេត និងប្រឹក្សាខាងផ្នែកប្រតិបត្តិច្បាប់របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរួចមក ក៏មាន

3 សម្រាប់ព័ត៌មានបន្ថែម សូមមើលឯកសាររបស់អង្គការអភិវឌ្ឍរួមជាអន្តរជាតិ "ប្រទេសកម្ពុជា និងឡាវ ៖ ការរំលោភយកដីចម្ការកៅស៊ូ" (ឆ្នាំ២០១៦) តាមរយៈ http://bit.ly/2aPg9Ag

សេចក្តីថ្លែងការណ៍ចុងក្រោយមួយបញ្ជាក់ពីចំណុចព្រមព្រៀងគ្នាត្រូវបានចេញនៅថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៦។ សេចក្តីថ្លែងការណ៍នេះរួមមានការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន HAGL ថាមិនឈូសឆាយ ឬអភិវឌ្ឍលើតំបន់របស់ជនជាតិដើមភាគតិចជាក់លាក់មួយចំនួន ព្រមទាំងត្រូវជួសជុល និងថែទាំផ្លូវថ្នល់ និងស្ពាននៅក្នុងភូមិដែលរងការខូចខាតដោយសារតែប្រតិបត្តិការរបស់ក្រុមហ៊ុនកន្លងមក។ ក៏មានការព្រមព្រៀងបន្ថែមទៀតថា ការប្តេជ្ញាចិត្តទាំងនេះនឹងត្រូវអនុវត្តតាមរយៈការរៀបចំទស្សនៈកិច្ចរួមគ្នាដំបូងដើម្បីកំណត់ផែនទីរួមនៅតាមភូមិដែលទទួលរងគ្រោះនីមួយៗ។

ដំណើរការដែលមានប្រាំមួយជំហានដូចដែលបានរៀបរាប់ខាងលើនេះផ្តល់នូវការណែនាំបង្ហាញផ្លូវដ៏មានប្រយោជន៍មួយចំពោះការអនុវត្តគោលការណ៍ណែនាំ។ ក៏ប៉ុន្តែ ដំណើរការដែលមានប្រាំមួយជំហាននោះនៅខ្វះខាតសេចក្តីលម្អិតជាក់លាក់នៅឡើយ។ ដ្យាក្រាមខាងក្រោមនេះ ផ្តល់នូវសំណើនៃជំហានអនុវត្តជាក់ស្តែងដែលធុរកិច្ចអាចយកទៅអនុវត្តគោលការណ៍ណែនាំ ៖



## ២.៤ ការផ្តល់ដំណោះស្រាយ

គោលការណ៍ណែនាំផ្តោតជាចម្បងទៅលើការទប់ស្កាត់កុំឱ្យមានការរំលោភបំពានសិទ្ធិមនុស្សតាំងពីដើមទីទៅ ប៉ុន្តែក៏ទទួលស្គាល់ដែរថា ប្រសិនបើមានការបំពានកើតឡើង ត្រូវមានយន្តការដោះស្រាយគ្រប់គ្រាន់យ៉ាងរឹងមាំរួចជាស្រេច។

ការផ្តល់យន្តការទទួលបានដំណោះស្រាយ គឺជាធាតុដ៏សំខាន់មួយនៃកាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ និងការទទួលខុសត្រូវរបស់ធុរកិច្ចក្នុងការគោរពសិទ្ធិមនុស្ស។ យន្តការបែបនេះ អាចជាយន្តការរដ្ឋ ឬមិនមែនរដ្ឋ ហើយអាចជាយន្តការតាមផ្លូវតុលាការ ឬអាចបញ្ចូលទៅជាបច្ចេកទេសដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។

គោលការណ៍ណែនាំ ប្រមើលឃើញមានយន្តការដំណោះស្រាយក្នុងទម្រង់ផ្សេងៗគ្នា ដូច្នេះយន្តការត្រូវធានាឱ្យមានភាពបត់បែនជាអតិបរមាសម្រាប់អ្នកប្រើប្រាស់និងដើម្បីងាយស្រួលប្រើប្រាស់។ ច្បាស់ណាស់ថា ប្រព័ន្ធតុលាការត្រូវតែជាតួអង្គដ៏សំខាន់មួយ។ ទោះជាយ៉ាងណាក៏ដោយ ការប្តឹងទៅតុលាការ គួរតែជាជម្រើសចុងក្រោយបំផុត ហើយគួរប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីដោះស្រាយជម្លោះដោយមិនចាំបាច់ត្រូវការអន្តរាគមន៍ពីតុលាការ។ ដូច្នេះហើយ វាជាការសំខាន់ណាស់ដែលត្រូវមានយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការដែលចេញពីធុរកិច្ច និងពីរដ្ឋ។

នៅក្នុងបរិបទប្រទេសកម្ពុជា បញ្ហាជាមួយនឹងយន្តការតុលាការរបស់រដ្ឋ ត្រូវបានគេសង្កត់ធ្ងន់ជាពិសេសដោយសារតែងតែមានបញ្ហាចោទលើឯករាជ្យភាព និងភាពឥតលម្អៀងរបស់តុលាការ ហើយអ្នកនយោបាយច្រើនតែប្រើប្រាស់តុលាការ ដើម្បីបង្ក្រាបអ្នកប្រឆាំង។ បញ្ហានេះត្រូវបានគេសង្កត់ធ្ងន់នៅក្នុងប្រទេសមួយដែលសកម្មភាពរបស់ធុរកិច្ចធំៗ និងរដ្ឋាភិបាលធំៗ មានការជាប់ពាក់ព័ន្ធយ៉ាងរឹងមាំ ដោយមានតុលាការដែលច្រើនតែដោះស្រាយជម្លោះដោយលម្អៀងទៅរកធុរកិច្ចដែលមានចំណងជាមួយនឹងរដ្ឋ។ បញ្ហាពាក់ព័ន្ធនឹងភាពលម្អៀងនៃប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាកាន់តែច្បាស់ខ្លាំង ជាពិសេស ពាក់ព័ន្ធនឹងជម្លោះដីធ្លី។

ចំពោះអ្នកដែលយល់ថាខ្លួនមានជាប់ពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លី បច្ចុប្បន្នមានយន្តការដោះស្រាយទំនាស់ចំនួន ៥។ យន្តការទាំង៥នេះរួមមាន ៖

១. **ក្រុមប្រឹក្សាឃុំ/សង្កាត់** ៖ ទោះជាក្រុមប្រឹក្សានេះខ្វះសមត្ថកិច្ចធ្វើសេចក្តីសម្រេចតាមផ្លូវច្បាប់ក្តី ក៏ក្រុមប្រឹក្សានេះអាចសម្របសម្រួលរវាងភាគីដើម្បី "ដោះស្រាយនូវការខ្វែងគំនិតគ្នា"។ ជាទូទៅ បណ្តឹងជាច្រើនជាដំបូងត្រូវដាក់នៅចំពោះមុខក្រុមប្រឹក្សាឃុំ/សង្កាត់ជាមុន ទោះបីវាមិនមែនជាលក្ខខណ្ឌតម្រូវក្តី។

២. **គណៈកម្មាធិការរដ្ឋបាល** ៖ គណៈកម្មាធិការនេះក៏ខ្វះសមត្ថកិច្ចចេញសេចក្តីសម្រេចចងកាតព្វកិច្ចដែរ។ គណៈកម្មាធិការរដ្ឋបាលមានប្រតិបត្តិការនៅគ្រប់តំបន់ទាំងអស់ និងជាអ្នកឆ្លើយតបដំបូងគេចំពោះបណ្តឹងដែលពាក់ព័ន្ធនឹងយុទ្ធនាការចុះបញ្ជីដីដែលឧបត្ថម្ភដោយរដ្ឋ (ការចុះបញ្ជីជាប្រព័ន្ធ)។

**៣. គណៈកម្មការសុរិយោដី** ៖ ស្ថាប័នចំណុះចំនួន ៣ ត្រូវបានបង្កើតឡើងក្រោមគណៈកម្មការសុរិយោដី ដើម្បីទទួលដោះស្រាយទំនាស់ពាក់ព័ន្ធនឹងដីមិនទាន់ចុះបញ្ជី និងទំនាស់ដែលមិនអាចដោះស្រាយបាន ដោយគណៈកម្មាធិការរដ្ឋបាលរួមមាន ថ្នាក់ស្រុក/ខណ្ឌ ថ្នាក់ខេត្ត/ក្រុង និងថ្នាក់ជាតិ។ ជម្លោះដីធ្លី ដែលប្ដឹងមកគណៈកម្មការសុរិយោដីត្រូវដោះស្រាយដំបូងគេនៅថ្នាក់ស្រុក/ខណ្ឌ ដែលមានសមត្ថកិច្ចត្រឹមតែជួយផ្សះផ្សាប៉ុណ្ណោះ។ ប្រសិនបើគ្មានការព្រមព្រៀងណាមួយនៅក្នុងកម្រិតនេះទេ ទំនាស់ត្រូវបញ្ជូនបន្តទៅថ្នាក់ខេត្ត/ក្រុង ដើម្បីព្យាយាមផ្សះផ្សាម្ដងទៀត ដែលថ្នាក់នេះមានអំណាច (ចាប់តាំងពីឆ្នាំ២០០៩) ក្នុងការចេញសេចក្ដីសម្រេច ប្រសិនបើគ្មានដំណោះស្រាយ។ ប្រសិនបើទំនាស់នៅតែមិនអាចដោះស្រាយបាននៅក្នុងកម្រិតស្រុក ឬខេត្ត ទំនាស់នេះត្រូវបញ្ជូនបន្តទៀតទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើការវិនិច្ឆ័យ។

**៤. អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** ៖ អាជ្ញាធរនេះទទួលពាក្យបណ្ដឹងលើសពីដែនសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី។ អាជ្ញាធរនេះមានឥទ្ធិពលលើដំណោះស្រាយទំនាស់ដីធ្លីដោយកំណត់ថាទំនាស់ណាត្រូវទទួលយកទំនាស់ណាត្រូវបញ្ជូនបន្តទៅស្ថាប័នផ្សេងទៀត (រួមទាំង តុលាការ) និងលក្ខណៈដែលបណ្ដឹងត្រូវធ្វើការស៊ើបអង្កេត។ សេចក្ដីសម្រេចរបស់អាជ្ញាធរនេះអាចប្ដឹងជំទាស់ទៅតុលាការបាន។

**៥. ប្រព័ន្ធតុលាការ** ៖ តុលាការមានយុត្តាធិការលើទំនាស់ដែលពាក់ព័ន្ធនឹងដីចុះបញ្ជី ឬដីមានប័ណ្ណកម្មសិទ្ធិ។ ប្រសិនបើភាគីមិនសុខចិត្ត ភាគីអាចប្ដឹងទៅសាលាឧទ្ធរណ៍បាន។ ភាគីដែលមិនសុខចិត្តដែលបានដាក់ពាក្យបណ្ដឹងទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក៏អាចប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍បានផងដែរ។ តុលាការមានយុត្តាធិការលើបណ្ដឹងពាក់ព័ន្ធនឹងការបណ្ដេញចេញដោយបង្ខំ ព្រមទាំងជម្លោះលើកិច្ចសន្យា និងជម្លោះរឿងមរតក ដោយមិនគិតថាដីនោះបានចុះបញ្ជីរួចហើយឬនៅនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើទំនាស់ពាក់ព័ន្ធនឹងដីមិនទាន់ចុះបញ្ជី ភាគីត្រូវតែដាក់ពាក្យបណ្ដឹងជាមុនទៅគណៈកម្មការសុរិយោដី។

ទោះវាច្បាស់លាស់ថា ប្រជាជនខ្មែរដែលទទួលរងគ្រោះពីទំនាស់ដីធ្លីមានយន្តការដោះស្រាយទំនាស់ជាច្រើនក្ដី យន្តការទាំងនេះបានបង្ហាញឱ្យឃើញថាភាគច្រើនគ្មានប្រសិទ្ធភាព និងមិនអាចធ្វើទៅបាន [4] ហេតុដូច្នេះហើយភាគច្រើន មិនអាចផ្ដល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាពបាននោះទេ។

រូបដ្យាក្រាមខាងក្រោមនេះបង្ហាញពីការណែនាំជុំវិញការយកទៅអនុវត្តនូវវិធានជាក់ស្ដែង រួមទាំងវិធានរបស់រដ្ឋ និងមិនមែនរដ្ឋ ដើម្បីសម្រេចឱ្យបានពេញលេញនូវគោលការណ៍ណែនាំ ៖

[4] សម្រាប់ព័ត៌មានបន្ថែមលើបញ្ហាទាក់ទិននឹងយន្តការដោះស្រាយទំនាស់ដីធ្លី សូមមើល ៖ ម.ស.ម.ក, "បរាជ័យនៃយន្តការដោះស្រាយទំនាស់ដីធ្លី" (របាយការណ៍) (ខែកក្កដា ឆ្នាំ២០១៤) តាមរយៈ http://goo.gl/SUJJUB




## ២.៥ ផលប្រយោជន៍នៃគោលការណ៍ណែនាំ

### ២.៥.១ តើគោលការណ៍ណែនាំមានប្រយោជន៍យ៉ាងដូចម្តេចខ្លះ ?

ស្របពេលការប្រកាន់ខ្ជាប់តាមគោលការណ៍ណែនាំ អាចទាមទារឱ្យមានការផ្លាស់ប្តូរមួយចំនួន ការអនុម័តគោលការណ៍នេះមិនត្រឹមតែអាចធានាថាសិទ្ធិមនុស្សត្រូវបានគោរពនៅក្នុងប្រតិបត្តិការធុរកិច្ចនោះទេ ការអនុវត្តគោលការណ៍នេះក៏អាចនាំមកនូវគុណសម្បត្តិជាច្រើនដល់អង្គភាពមួយចំនួននៅក្នុងប្រទេសកម្ពុជាថែមទៀតផង រួមទាំងគុណសម្បត្តិសម្រាប់រដ្ឋាភិបាលផង និងសម្រាប់ធុរកិច្ចខ្លួនឯងផង។ ខាងក្រោមនេះ ជាការរៀបរាប់អំពីផលប្រយោជន៍សំខាន់ៗមួយចំនួនដែលការអនុវត្តតាមគោលការណ៍ណែនាំនេះ នឹងបង្កើតបាន ៖

#### *២.៥.១.១ រាជរដ្ឋាភិបាលកម្ពុជា*

- **បង្កើនទំនុកចិត្តរបស់វិនិយោគិន** ៖ តាមរយៈការលើកកម្ពស់បរិស្ថានដែលអាចសម្រួលដល់ការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសពីប្រទេសលោកខាងលិច។
- **ការកាត់បន្ថយហានិភ័យ** ៖ គោលការណ៍ណែនាំនឹងជួយកាត់បន្ថយហានិភ័យរបស់រដ្ឋាភិបាលកម្ពុជាចំពោះការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

- **ភាពស៊ីសង្វាក់ផ្នែកគោលនយោបាយ ៖** គោលការណ៍ណែនាំផ្តល់នូវការណែនាំដល់អ្នកបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលជុំវិញការត្រួតពិនិត្យដ៏ត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស។
- **ការទទួលបានដំណោះស្រាយ ៖** ដោយសារតែរដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការធានាឱ្យអាចរកបាននូវយន្តការដំណោះស្រាយយោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ គោលកាណ៍ណែនាំទាំងនេះផ្តល់នូវក្របខណ្ឌមួយមានប្រយោជន៍។

### *២.៥.១.២ ធុរកិច្ច*

- **បង្កើនកិត្តិយសផ្នែកជំនួញ ៖** ដោយការអនុវត្តគោលការណ៍ណែនាំ នឹងជួយធុរកិច្ចក្នុងការអនុលោមជាមួយសិទ្ធិមនុស្ស ដែលនឹងជួយពង្រឹងពង្រីកកិត្តិយសរបស់ពួកគេ។
- **ការចូលរួមរបស់រដ្ឋាភិបាល ៖** គោលការណ៍ណែនាំនេះជំរុញឱ្យមានការពិភាក្សាអំពីបញ្ហាសំខាន់ៗរវាងរដ្ឋាភិបាល និងធុរកិច្ច។
- **ការកាត់បន្ថយហានិភ័យ ៖** តាមរយៈការអនុវត្តគោលការណ៍ណែនាំ ជួយក្នុងការកាត់បន្ថយហានិភ័យនៃការប្តឹងផ្តល់គ្នា។
- **មិនមានការខាតបង់ឱកាស ៖** ការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្សនឹងទប់ស្កាត់មិនឱ្យមានការបាត់បង់ដែលកើតចេញពីការតវ៉ារបស់កម្មករ ការខ្វះខាតការពេញចិត្តរបស់អតិថិជន និងការមិនអនុលោមតាមបទដ្ឋានអតិថិជន។
- **បង្កើនផលិតភាព ៖** ផ្តោតលើការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្សនឹងជួយបង្កើនផលិតភាព ប្រសិនបើនិយោជិតមានការពេញចិត្តធ្វើការនៅកន្លែងដែលមានសុវត្ថិភាពនិងមានការធានាសិទ្ធិ។
- **ភាពប្រកួតប្រជែង ៖** ការប្រតិបត្តិការដោយប្រើប្រាស់គោលការណ៍ណែនាំ និងការប្តេជ្ញាចិត្តចំពោះសិទ្ធិមនុស្ស នឹងជំរុញឱ្យមានភាពចំណេញរបស់ក្រុមហ៊ុននៅក្នុងទីផ្សារ។
- **ការអភិវឌ្ឍសង្វាក់តម្លៃ ៖** អ្នកទិញនិងអ្នកផ្គត់ផ្គង់ ទទួលផលប្រយោជន៍ពីទំនាក់ទំនងដែលមានភាពល្អប្រសើរ និងផលិតភាពដែលមានការកើនឡើង នៅពេលក្រុមហ៊ុនគោរពសិទ្ធិមនុស្ស។
- **និរន្តរភាព ៖** ជាមួយនឹងផលិតភាពកើនឡើង និងការអនុវត្តធុរកិច្ចប្រកបដោយក្រមសីលធម៌នោះ ធុរកិច្ចនឹងមានឱកាសកាន់តែច្រើនក្នុងការបន្ត និងពង្រីកសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន។
- **ឱកាសកើនឡើងក្នុងការពង្រីក និងចូលរួមក្នុងទីផ្សារនាំចេញ ៖** ការអនុវត្តគោលការណ៍ណែនាំនឹងបង្កើតការបើកចំហសម្រាប់ទីផ្សារទាំងឡាយ ដែលទាមទារបទដ្ឋានមួយចំនួនទាក់ទងនឹងភាពដែលអាចតាមដានបាន មាននិរន្តរភាព មានការបញ្ជាក់ត្រឹមត្រូវ និងមានការអនុវត្តធុរកិច្ចល្អ (ឧទាហរណ៍ទីផ្សារអឺរ៉ុប និងអាមេរិក)។

### *២.៥.១.៣ អង្គការសង្គមស៊ីវិល និងបុគ្គល/សហគមន៍រងការប៉ះពាល់*

- គោលការណ៍ណែនាំ នឹងជានាឱ្យមាន**បទដ្ឋានតាមដានសិទ្ធិមនុស្ស** ស្រដៀងគ្នានៅក្នុងវិស័យធុរកិច្ច និងសង្គមស៊ីវិល។
- គោលការណ៍ណែនាំ ផ្តល់**បទដ្ឋានរួមក្នុងការចូលរួម**រវាងភាគីពាក់ព័ន្ធ ដូច្នេះហើយ វាជានាថាគ្រប់គ្នាមានការយល់ដឹងដូចគ្នាអំពីអ្វីដែលត្រូវសម្រេចឱ្យបាន។

### *២.៥.១.៤ ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍ*

- គោលការណ៍ណែនាំនឹងជួយដល់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍ រាប់បញ្ចូលទាំងស្ថាប័នហិរញ្ញវត្ថុពហុភាគី ដែលផ្តល់ការគាំទ្រ និងជំនួយក្នុងប្រទេសដែលពួកគេប្រតិបត្តិការក្នុង**ការជ្រើសរើសដៃគូ** (ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល សហគមន៍ បុគ្គល និងភាគីទីបីផ្សេងទៀត ដោយរាប់បញ្ចូលទាំងធុរកិច្ចប្រឹក្សាយោបល់ឯកជន និងទីភ្នាក់ងារពីខាងក្រៅទៀតផង)។
- គោលការណ៍ណែនាំ ផ្តល់នូវ**ឯកសារយោងរួមមួយទាក់ទងនឹងជំនួយ និងការគាំទ្រ**របស់ពួកគេក្នុងការជានាថាស្ថាប័នទាំងនោះ មិនរារាំងដល់សមត្ថភាពរបស់រដ្ឋជាសមាជិកក្នុងការបំពេញភារកិច្ចក្នុងការការពារ ហើយក៏មិនរារាំងសហគ្រាសធុរកិច្ចពីការគោរពសិទ្ធិមនុស្សដែរ។

# ៣. គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ

## ៣.១ តើគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ គឺជាអ្វី?

គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ គឺជាបណ្តុំអនុសាសន៍ដែលរៀបរៀងឡើងដោយរដ្ឋាភិបាលនានាសម្រាប់សហគ្រាសពហុជាតិ។ គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ មិនត្រឹមតែដោះស្រាយផលប៉ះពាល់របស់ធុរកិច្ចលើសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ដាក់ចេញនូវការអនុវត្តល្អៗសម្រាប់សហគ្រាសពហុជាតិផងដែរ។

ខុសពីគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ មិនមានលក្ខណៈជាសកលនោះទេ ដោយគោលការណ៍ណែនាំនេះអនុវត្តតែទៅលើសហគ្រាសពហុជាតិដែលប្រតិបត្តិការនៅក្នុង ឬពីដែនដីរបស់រដ្ឋាភិបាលដែលបានឯកភាពលើគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិប៉ុណ្ណោះ។ គិតមកត្រឹមខែមិថុនា ឆ្នាំ២០១៦ រដ្ឋចំនួន ៤៦ ឯកភាពគោរពតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិរួមមានរដ្ឋ ៣៥ ជារដ្ឋសមាជិករបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ និងរដ្ឋ ១១ បន្ថែមទៀត រួមទាំងរដ្ឋដែលទើបមានសេដ្ឋកិច្ចរីកលូតលាស់មួយចំនួនដូចជា ប្រេស៊ីល កូឡុំប៊ី និងអាហ្សង់ទីន។ ខណៈដែលប្រទេសកម្ពុជាមិនទាន់ឯកភាពលើគោលការណ៍ណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ប៉ុន្តែសហគ្រាសធុរកិច្ចអន្តរជាតិជាច្រើនកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាមានទីស្នាក់ការនៅក្នុងរដ្ឋ ដែលជាសមាជិករបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ ហេតុដូច្នេះសកម្មភាពធុរកិច្ចរបស់សហគ្រាសទាំងនេះនៅកម្ពុជាស្ថិតក្នុងវិសាលភាពនៃគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ដូច្នេះត្រូវអនុវត្តតាមអនុសាសន៍នៃគោលការណ៍ណែនាំនេះ។




## ៣.២ តើគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ និយាយអ្វីខ្លះអំពីបញ្ហាសិទ្ធិមនុស្ស?

គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ត្រូវបានអនុម័តដំបូងនៅក្នុងឆ្នាំ១៩៧៦ ប៉ុន្តែត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពចំនួន ៥ លើកចាប់តាំងពីពេលនោះមក។ ការកែសម្រួលចុងក្រោយបំផុតគឺនៅឆ្នាំ២០១១ ដោយបានដាក់បញ្ចូលជាលើកដំបូងនូវជំពូកស្តីពីសិទ្ធិមនុស្ស និងត្រូវបានតាក់តែងឡើង ដើម្បីឱ្យមានភាពស្របគ្នាជាមួយនឹងក្របខណ្ឌស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ" និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ។

ខណៈដែលមានការទទួលស្គាល់ថាភារកិច្ចគោរពសិទ្ធិមនុស្សស្ថិតនៅលើរដ្ឋ គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ផ្តល់អនុសាសន៍ថាសហគ្រាសពហុជាតិត្រូវ ៖

- គោរពសិទ្ធិមនុស្ស
- ជៀសវាងការបង្ក ឬរួមចំណែកនាំឱ្យមានផលប៉ះពាល់មិនល្អលើបញ្ហាសិទ្ធិមនុស្ស និងដោះស្រាយផលប៉ះពាល់ទាំងនោះនៅពេលកើតឡើង
- បង្ការ ឬសម្រាលដល់ផលប៉ះពាល់មិនល្អលើបញ្ហាសិទ្ធិមនុស្សដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រតិបត្តិការធុរកិច្ចរបស់ខ្លួន និងមានការប្តេជ្ញាចិត្តតាមរយៈគោលនយោបាយក្នុងការគោរពសិទ្ធិមនុស្ស
- ធ្វើការត្រួតពិនិត្យដ៏ត្រឹមត្រូវលើបញ្ហាសិទ្ធិមនុស្ស និង

- ផ្តល់ដំណោះស្រាយនៅពេលដែលក្រុមហ៊ុនបានបង្ក ឬរួមចំណែកនាំឱ្យមានផលប៉ះពាល់មិនល្អដល់សិទ្ធិមនុស្ស។[5]

ខណៈដែលចំណុចខាងលើគ្រាន់តែជាអនុសាសន៍ និងមិនបង្កើតជាកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់សហគ្រាសពហុជាតិ តែប្រព័ន្ធគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ក៏ដាក់ភារកិច្ចតាមផ្លូវច្បាប់មួយចំនួនដល់រដ្ឋដែលកំពុងតែអនុវត្តគោលការណ៍នេះ។ ដោយឡែក រដ្ឋមានកាតព្វកិច្ចបង្កើតឱ្យមានស្ថាប័នបង្គោលថ្នាក់ជាតិមួយ ដែលជាយន្តការដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលទទួលខុសត្រូវលើការលើកកម្ពស់គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ (សូមមើលផ្នែកទី ៣.៣ ខាងក្រោម)។ រដ្ឋាភិបាលក៏ត្រូវបានរំពឹងថានឹងអនុវត្តតាមគោលការណ៍ណែនាំនេះ (ដែលអនុវត្តដូចគ្នាចំពោះសហគ្រាសពហុជាតិដែលជាកម្មសិទ្ធិទាំងស្រុង ឬដោយផ្នែករបស់រដ្ឋ) និងជំរុញឱ្យសហគ្រាសពហុជាតិប្រើប្រាស់គោលការណ៍នេះ ព្រមទាំងអនុម័តច្បាប់ និងគោលនយោបាយនានាដើម្បីជួយបង្កើតបរិយាកាសមួយដែលគាំទ្រធុរកិច្ចឱ្យធ្វើប្រតិបត្តិការប្រកបដោយការទទួលខុសត្រូវ។

## ៣.៣ ការប្រើប្រាស់គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិនៅក្នុងស្ថានភាពជាក់ស្តែង

គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ អាចជាឧបករណ៍ដ៏មានឥទ្ធិពលមួយសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងការងាររបស់ខ្លួនដើម្បីបង្ការ និងប្រឆាំងនឹងការបំពានសិទ្ធិមនុស្សដែលបង្កដោយធុរកិច្ច។ គោលការណ៍នេះអាចជួយផ្លាស់ប្តូរឥរិយាបថរបស់សាជីវកម្ម បង្កើនការយល់ដឹងជាសាធារណៈ និងផ្តល់យន្តការសម្រាប់ដោះស្រាយបណ្តឹង។

គោលការណ៍នេះផ្តល់នូវបទដ្ឋានច្បាស់លាស់ និងមានឥទ្ធិពលមួយប្រឆាំងនឹងសកម្មភាពធុរកិច្ចទាំងឡាយណាដែលអាចត្រូវបានវិនិច្ឆ័យ។ ជាលទ្ធផល សេចក្តីថ្លែងការណ៍មួយរបស់អង្គការសង្គមស៊ីវិលដែលភ្ជាប់ការរំលោភបំពានសិទ្ធិមនុស្សពីសំណាក់សហគ្រាសពហុជាតិទៅនឹងគោលការណ៍នេះនឹងជួយបង្កើនការយល់ដឹងជាសាធារណៈ ដោយសារតែការលើកឡើងបែបនេះនឹងបញ្ជាក់យ៉ាងច្បាស់អំពីការខកខានជាក់លាក់ណាមួយរបស់សហគ្រាសពហុជាតិក្នុងការគោរពតាមគោលការណ៍ ចង្អុលបង្ហាញអំពីភាពធ្ងន់ធ្ងរ និងធ្វើដូចនេះនៅក្នុងលក្ខខណ្ឌទទួលស្គាល់ជាសកលដែលអាចឱ្យសាធារណជន សារព័ត៌មាន និងអង្គការតស៊ូមតិនានានៅក្នុង និងក្រៅប្រទេសកម្ពុជាបានយល់ដឹង។ ដោយសារសំណុំបទដ្ឋានទាំងនេះត្រូវបានរដ្ឋាភិ បាល សង្គមស៊ីវិល និងធុរកិច្ចឯកភាពរួចហើយ គោលការណ៍នេះក៏អាចជាចំណុចចាប់ផ្តើមដែលមានប្រយោជន៍រួមមួយសម្រាប់សង្គមស៊ីវិលនៅក្នុងការចាប់ផ្តើមកិច្ចសន្ទនាជាមួយសហគ្រាសពហុជាតិជុំវិញការប្រព្រឹត្តរបស់សហគ្រាសទាំងនេះ។

---

[5] គោលការណ៍អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ (កំណែ ឆ្នាំ២០១១), ជំពូកទី ៦ តាមរយៈ http://bit.ly/1kPDOqW

បន្ថែមពីលើការជួយបង្កើនការយល់ដឹងអំពីការរំលោភបំពានសិទ្ធិមនុស្សពីវិស័យធុរកិច្ច គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ក៏អាចផ្តល់ជាមធ្យោបាយមួយក្នុងការបំពេញដល់សសរស្តម្ភទី ៣ នៃក្របខណ្ឌស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ តាមរយៈការផ្តល់នូវការទទួលបានដំណោះស្រាយពីការរំលោភបំពានសិទ្ធិមនុស្ស។ គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ មានលក្ខណៈពិសេសក្នុងន័យដែលថាគោលការណ៍នេះជាលិខិតុបករណ៍អន្តរជាតិស្តីពីការទទួលខុសត្រូវរបស់សាជីវកម្មតែមួយគត់ ដែលមានយន្តការដោះស្រាយបណ្តឹងជាប់ជាមួយនឹងគោលការណ៍ផ្ទាល់តែម្តង គឺស្ថាប័នបង្គោលថ្នាក់ជាតិ ដែលអង្គការសង្គមស៊ីវិល និងបុគ្គលអាចប្រើប្រាស់បានដោយផ្ទាល់។




មុខងារសំខាន់មួយរបស់ស្ថាប័នបង្គោលថ្នាក់ជាតិ គឺជួយដោះស្រាយបញ្ហាដែលកើតចេញពីការ(មិន) អនុវត្តតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ក្នុងស្ថានភាពជាក់ស្តែងដោយប្រើប្រាស់ការិយាល័យគំរូរបស់ពួកគេ។ មុខងារនេះធ្វើឡើងតាមរយៈដំណើរការក្នុង "ករណីជាក់លាក់" ដែលអនុញ្ញាតឱ្យភាគីដែលមានប្រយោជន៍ពាក់ព័ន្ធដូចជាធុរកិច្ច សហជីពកម្មករ និងអង្គការសង្គមស៊ីវិលលើកពីបញ្ហា ដែលខ្លួនយល់ថាសហគ្រាសពហុជាតិមិនធ្វើសកម្មភាពអនុលោមតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ទៅកាន់ស្ថាប័នបង្គោលថ្នាក់ជាតិ។ នៅពេលសហគ្រាសពហុជាតិដែលមានទីស្នាក់ការនៅក្នុងប្រទេសដែលគោរពតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ កំពុងរំលោភបំពានសិទ្ធិមនុស្សនៅកម្ពុជា អង្គការសង្គមស៊ីវិលអាចគិតពិចារណាពីការដាក់ពាក្យបណ្តឹងទៅស្ថាប័នបង្គោលថ្នាក់ជាតិនៃប្រទេសដើមកំណើតរបស់សហគ្រាសពហុជាតិនោះ។ គោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ប្រមូលផ្តុំអនុសាសន៍យ៉ាងទូលំទូលាយសម្រាប់ឱ្យសហគ្រាសពហុជាតិ "គោរព

សិទ្ធិមនុស្ស" ដូច្នេះវាទំនងដែលថាទម្រង់នៃការរំលោភបំពានសិទ្ធិមនុស្សភាគច្រើនបំផុតនឹងស្ថិតក្នុងវិសាលភាពនៃគោលការណ៍នេះ។ នៅក្នុងការដាក់ពាក្យបណ្តឹង អង្គការសង្គមស៊ីវិលគប្បីត្រូវប្រាកដថា ខ្លួនបញ្ជាក់ពីបទប្បញ្ញត្តិណាខ្លះនៃគោលការណ៍ដែលត្រូវបានបំពាន បញ្ជាក់ពីជនរងគ្រោះ និងសហគ្រាសពហុជាតិដែលពាក់ព័ន្ធ ព្រមទាំងបញ្ជាក់ពីលទ្ធផលដែលខ្លួនចង់បាន ដូចជាការកែប្រែគោលនយោបាយ ឬឥរិយាបថរបស់ក្រុមហ៊ុន ឬវិធានការដោះស្រាយការខូចខាតដែលបានបង្កឡើង។[6]

ជាដំបូងស្ថាប័នបង្គោលថ្នាក់ជាតិនឹងពិចារណាថាបញ្ហា ដែលលើកឡើងមកនោះតម្រូវឱ្យមានការត្រួតពិនិត្យបន្ថែមដែរឬទេ ហើយប្រសិនបើតម្រូវឱ្យមានការត្រួតពិនិត្យបន្ថែម ស្ថាប័នបង្គោលថ្នាក់ជាតិនឹងប្រឹក្សាយោបល់ជាមួយនឹងភាគី និងដៃគូ ព្រមទាំងផ្តល់ជំនួយតាមការិយាល័យគំរូដើម្បីជួយដោះស្រាយបញ្ហានោះតាមរយៈការផ្សះផ្សា ឬសម្របសម្រួល។ គ្រប់បណ្តឹងទាំងអស់ ស្ថាប័នបង្គោលថ្នាក់ជាតិនឹងចេញសេចក្តីថ្លែងការណ៍ ឬរបាយការណ៍មួយ។

អង្គការសង្គមស៊ីវិលបានសម្តែងកង្វល់អំពីភាពខ្វះចន្លោះមួយចំនួននៅក្នុងប្រព័ន្ធស្ថាប័នបង្គោលថ្នាក់ជាតិ[7] ដូចជាកង្វះតម្លាភាព និងភាពលម្អៀងជាក់ស្តែង ឬភាពដែលអាចលម្អៀង ដោយហេតុថាស្ថាប័នបង្គោលថ្នាក់ជាតិស្ថិតនៅក្នុងក្រុមខណ្ឌរដ្ឋាភិបាលនៃប្រទេសដែលគោរពតាមគោលការណ៍ណែនាំ។ ដូចគ្នានេះដែរ ការដាក់ពាក្យបណ្តឹងទៅស្ថាប័នបង្គោលថ្នាក់ជាតិមិនមែនតែងតែជាមធ្យោបាយល្អបំផុតនោះទេ ហើយអង្គការសង្គមស៊ីវិលត្រូវពិចារណាគ្រប់ជម្រើសទាំងអស់ដែលមាន៖ ពួកគាត់អាចប្តឹងទៅតុលាការ ឬព្យាយាមប្រើឥទ្ធិពលលើសហគ្រាសពហុជាតិតាមរយៈការបញ្ចុះបញ្ចូល និងយុទ្ធនាការជាសាធារណៈ។ ពេលខ្លះ សហគ្រាសពហុជាតិគ្មានឆន្ទៈចូលរួមតាមរយៈដំណើរការសម្របសម្រួលរបស់ស្ថាប័នបង្គោលថ្នាក់ជាតិនោះទេ ប្រសិនបើវាជាគោលដៅដែលអាចមានយុទ្ធនាការសាធារណៈ ឬសកម្មភាពតាមផ្លូវច្បាប់ក្នុងពេលជំណាលគ្នានោះ។

ប៉ុន្តែ នៅពេលដែលសហគ្រាសពហុជាតិ និងជនរងគ្រោះមានឆន្ទៈចូលរួម និងស្វែងរកដំណោះស្រាយដែលភាគីអាចទទួលយកបាន បណ្តឹងដែលដាក់ទៅស្ថាប័នបង្គោលថ្នាក់ជាតិនឹងមានប្រសិទ្ធភាព។ នៅក្នុងដំណើរការរយៈពេល ១៥ ឆ្នាំនៃប្រព័ន្ធស្ថាប័នបង្គោលថ្នាក់ជាតិផ្តល់ផលវិជ្ជមានសំខាន់ៗមួយចំនួន ដែលបង្ហាញថា ប្រព័ន្ធនេះអាចជាមធ្យោបាយមានប្រយោជន៍មួយសម្រាប់អ្នកដែលទទួលរងផលអវិជ្ជមានផ្នែកសិទ្ធិមនុស្សពីវិស័យធុរកិច្ចក្នុងការទទួលបានដំណោះស្រាយ។ យោងតាមទិន្នន័យផ្ទាល់របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ ចន្លោះពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ ករណីជាក់លាក់ប្រហែលជាពាក់កណ្តាល ដែលទទួលយកដោយស្ថាប័នបង្គោលថ្នាក់ជាតិ ត្រូវបានដោះស្រាយតាមការព្រមព្រៀងរវាងភាគី ហើយប្រមាណ

---

[6] សម្រាប់គោលការណ៍លម្អិតបន្ថែមស្តីពីការដាក់ពាក្យបណ្តឹងទៅកាន់ស្ថាប័នបង្គោលថ្នាក់ជាតិ សូមមើលគម្រោងឃ្លាំមើលរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់, "ការអំពាវនាវឱ្យមានគណនេយ្យភាពសាជីវកម្ម ៖ ការណែនាំលើគោលការណ៍ណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់ ឆ្នាំ២០១១ សម្រាប់សហគ្រាសពហុជាតិ (ខែមិថុនា ឆ្នាំ ២០១៣) តាមរយៈ http://bit.ly/29ZRBeb

[7] សូមមើលគម្រោងឃ្លាំមើលរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ, "ដំណោះស្រាយនៅមានតិចតួចនៅឡើយ" (ខែមិថុនា ឆ្នាំ២០១៥) តាមរយៈ http://bit.ly/1QDkzNc

៣៦% ដោះស្រាយបានតាមការកែប្រែគោលនយោបាយផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលជាភាគី ដែលនេះជាការរួមចំណែកដល់ការបង្ការផលប៉ះពាល់មិនល្អនាពេលអនាគត។[8] ករណីសិក្សាខាងក្រោមនេះនឹងផ្តល់ជាឧទាហរណ៍អំពីករណីជោគជ័យមួយ ៖

**ករណី ៖ បណ្តឹងរបស់មូលនិធិអភិរក្សសត្វព្រៃពិភពលោកអន្តរជាតិប្តឹងក្រុមហ៊ុនអន្តរជាតិសាធារណៈសូកូ**

នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៣ មូលនិធិអភិរក្សសត្វព្រៃពិភពលោក (WWF) បានដាក់ពាក្យបណ្តឹងទៅស្ថាប័នបង្គោលថ្នាក់ជាតិនៅក្នុងចក្រភពអង់គ្លេស។ ពាក្យបណ្តឹងនោះលើកឡើងថាក្រុមហ៊ុនសូកូ បានធ្វើសកម្មភាពរុករកប្រេងនៅក្នុងឧទ្យានជាតិវីរ៉ុនហ្គា (Virunga) នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ("ប្រទេសកុងហ្គោ") និងថាសកម្មភាពទាំងនោះត្រូវបានហាមឃាត់ក្រោមកិច្ចព្រមព្រៀងអន្តរជាតិ និងច្បាប់របស់ប្រទេសកុងហ្គោ (ជាពិសេស សកម្មភាពទាំងនោះមិនអនុលោមតាមលក្ខខណ្ឌនៃតំបន់បេតិកភណ្ឌពិភពលោករបស់ឧទ្យានជាតិនេះ) និងបានបង្កឱ្យមានផលប៉ះពាល់មិនល្អដល់បរិស្ថាន និងសហគមន៍នានានៅមូលដ្ឋាន។ ក្រុមហ៊ុនសូកូ បានឆ្លើយតបនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ និងបានច្រានចោលការចោទប្រកាន់ទាំងនេះ ដោយលើកឡើងថា សកម្មភាពរបស់ខ្លួននៅក្នុងឧទ្យានជាតិផ្តោតត្រឹមតែការសិក្សាពីបរិស្ថាន វិទ្យាសាស្រ្ត និងសង្គម ហើយថាសកម្មភាពរបស់ខ្លួនមិនបានបង្កផលប៉ះពាល់មិនល្អធ្ងន់ធ្ងរណាមួយដល់តំបន់ ឬសហគមន៍មូលដ្ឋានឡើយ។ ស្ថាប័នបង្គោលថ្នាក់ជាតិបានទទួលយកជាតុផ្សំនៃពាក្យបណ្តឹងពាក់ព័ន្ធនឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ សិទ្ធិមនុស្ស និងអនុសាសន៍ផ្នែកបរិស្ថាន ស្របតាមគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ និងផ្តល់លទ្ធភាពដល់ភាគីក្នុងការប្រើប្រាស់យន្តការស្ថាប័នបង្គោលថ្នាក់ជាតិ សម្រាប់ដោះស្រាយបញ្ហារបស់ពួកគេដោយប្រើប្រាស់អ្នកសម្រុះសម្រួលមកពីខាងក្រៅ។

ភាគីទាំងសងខាងបានព្រមព្រៀងចូលរួម ហើយបន្ទាប់ពីឆ្លងកាត់ការសម្រុះសម្រួលរួច គូភាគីក៏បានព្រមព្រៀងគ្នា។ ក្រុមហ៊ុនសូកូ បានប្តេជ្ញាបញ្ឈប់ប្រតិបត្តិការរបស់ខ្លួននៅក្នុងតំបន់វីរ៉ុនហ្គា ក្នុងរយៈពេល ៣០ ថ្ងៃ និងមិនធ្វើសកម្មភាពខួងរុករកផ្សេងទៀតនៅក្នុងឧទ្យានជាតិវីរ៉ុនហ្គា ឡើយ លើកលែងតែអង្គការយូនេស្កូ (UNESCO) និងរដ្ឋាភិបាលកុងហ្គោឯកភាពថាសកម្មភាពទាំងនោះអនុលោមតាមលក្ខខណ្ឌនៃតំបន់បេតិកភណ្ឌពិភពលោក។ ក្រុមហ៊ុនសូកូ ក៏បានប្តេជ្ញាមិនធ្វើប្រតិបត្តិការនៅក្នុងតំបន់បេតិកភណ្ឌពិភពលោកផ្សេងទៀតទូទាំងសកលលោកដែរ។ ក្នុងន័យនេះ អង្គការ WWF បានព្រមព្រៀងបញ្ឈប់ការប្តឹងផ្តល់ទៀត។

កិច្ចព្រមព្រៀងរវាងអង្គការ WWF និងក្រុមហ៊ុនសូកូ គឺជាលើកទីមួយហើយដែលក្រុមហ៊ុនឯកជនបានព្រមព្រៀងបញ្ឈប់ប្រតិបត្តិការរបស់ខ្លួននៅក្នុងដំណាក់កាលនៃការសម្រុះសម្រួលក្រោមការជួយជ្រោមជ្រែងរបស់ស្ថាប័នបង្គោលថ្នាក់ជាតិ។

---

[8] អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់, "ការអនុវត្តគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ៖ ស្ថាប័នបង្គោលថ្នាក់ជាតិចាប់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥" (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦) តាមរយៈ http://bit.ly/29eOCif

## ៣.៤ ការអនុវត្តគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ សម្រាប់សហគ្រាសពហុជាតិនៅក្នុងបរិបទកម្ពុជា

សហគ្រាសពហុជាតិមិនត្រឹមតែត្រូវបានគេរំពឹងថានឹងអនុវត្តតាមអនុសាសន៍នៃគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ នៅក្នុងប្រតិបត្តិការរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែផ្នែកសំខាន់មួយនៃប្រព័ន្ធគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ក៏មានការរំពឹងថាសហគ្រាសពហុជាតិនឹងអនុវត្តការត្រួតពិនិត្យដ៏ត្រឹមត្រូវក្នុងការកំណត់ បង្ការ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានជាផ្នែកនៃខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន ឬតាមរយៈសកម្មភាពដែលភ្ជាប់ដោយទំនាក់ទំនងធុរកិច្ចផងដែរ។ ករណីនេះពាក់ព័ន្ធជាពិសេសនៅក្នុងបរិបទកម្ពុជា ដែលជាឧទាហរណ៍ រោងចក្រ និងចម្ការក្នុងស្រុកខ្មែរជាប្រភពនៃវត្ថុធាតុដើមសម្រាប់សហគ្រាសពហុជាតិបរទេស ដូចជាសម្លៀកបំពាក់ ឬស្ករសជាដើម។ នៅពេលដែលសហគ្រាសពហុជាតិមិនបានយកចិត្តទុកដាក់ខ្លាំងឱ្យបានគ្រប់គ្រាន់ ពួកគាត់អាចខកខានក្នុងការបំពេញតាមការទទួលខុសត្រូវរបស់ខ្លួនស្របតាមគោលការណ៍នេះ ដែលករណីនេះអាចបង្កើតជាមូលដ្ឋានសម្រាប់ឱ្យអង្គការសង្គមស៊ីវិលធ្វើយុទ្ធនាការ ឬដាក់ពាក្យបណ្តឹងទៅស្ថាប័នបង្គោលថ្នាក់ជាតិដែលពាក់ព័ន្ធ។

ដោយមានការពិភាក្សាជាមួយធុរកិច្ច សហជីព និងសង្គមស៊ីវិល អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍបានបង្កើតជាបណ្តុំនៃសេចក្តីណែនាំសម្រាប់សហគ្រាសពហុជាតិអំពីរបៀបអនុវត្តគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ។ ដើម្បីឱ្យសហគ្រាសពហុជាតិធ្វើការយកចិត្តទុកដាក់ខ្លាំងក្នុងការធានាថាខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួនមិនបង្កផលប៉ះពាល់អវិជ្ជមានណាមួយ រួមទាំងសិទ្ធិមនុស្សនោះ សហគ្រាសពហុជាតិគប្បី ៖



១. **<u>បង្កើតប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុនដ៏រឹងមាំមួយ</u>** ៖ ឧទាហរណ៍ សហគ្រាសពហុជាតិនីមួយៗគួរតែមានគោលនយោបាយក្រុមហ៊ុនច្បាស់លាស់មួយស្តីពីបទដ្ឋានក្រមសីលធម៌នៃធុរកិច្ចប្រកបដោយការទទួលខុសត្រូវ ដែលខ្លួនប្តេជ្ញាគោរពតាម ដូចជាគោលនយោបាយសិទ្ធិមនុស្ស និងបរិស្ថាន។

២. **<u>កំណត់ វាយតម្លៃ និងផ្តល់អាទិភាពដល់ហានិភ័យនៃផលប៉ះពាល់អវិជ្ជមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់</u>** ៖ របៀបអនុវត្តសកម្មភាពនេះតាមទិដ្ឋភាពជាក់ស្តែងអាស្រ័យលើវិស័យដែលសហគ្រាសពហុជាតិធ្វើប្រតិបត្តិការ។ ក្រុមហ៊ុនមួយដែលប្រមូលទិញផលិតផលវាយនភ័ណ្ឌពីរោងចក្រគ្រប់គ្រងដោយឯករាជ្យនៅក្នុងប្រទេសកម្ពុជា នឹងជួបបញ្ហាប្រឈមផ្សេងនៅក្នុងការព្យាយាមកំណត់ពីហានិភ័យខុសពីក្រុមហ៊ុនដែលកាន់កាប់ដីធ្លីនៅកម្ពុជា និងធ្វើចម្ការផ្ទាល់ខ្លួន។

៣. **<u>រៀបចំ និងអនុវត្តយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលបានកំណត់រួច</u>** ៖ ប្រសិនបើសហគ្រាសពហុជាតិរកឃើញថាខ្សែសង្វាក់ផ្គត់ផ្គង់ ឬដៃគូធុរកិច្ចរបស់ខ្លួនអាចបង្កើតឱ្យមានហានិភ័យនៃផលប៉ះពាល់អវិជ្ជមានលើបញ្ហាសិទ្ធិមនុស្ស (ឧទាហរណ៍ ការបណ្តេញចេញដោយបង្ខំ ឬការរំលោភបំពានលើសិទ្ធិការងារ) សហគ្រាសនោះគួរតែចាត់វិធានការសមស្របដើម្បីជួយសម្រាលការខូចខាតទាំងនេះ ឧទាហរណ៍ តាមរយៈការចូលរួមជាមួយសហគមន៍មូលដ្ឋាន ការផ្តល់សំណងគ្រប់គ្រាន់ ឬបដិសេធធ្វើការជាមួយនឹងអ្នកផ្គត់ផ្គង់ក្នុងស្រុក រហូតទាល់តែមានការអនុវត្តស្របតាមបទដ្ឋានពលកម្មជាដើម។

៤. **<u>ផ្ទៀងផ្ទាត់ការយកចិត្តទុកដាក់ខ្លាំងលើខ្សែសង្វាក់ផ្គត់ផ្គង់</u>** ៖ ឧទាហរណ៍ តាមរយៈប្រព័ន្ធសវនកម្មឯករាជ្យធ្វើឡើងដោយភាគីទី៣។

៥. **<u>ចុះផ្សាយរបាយការណ៍ជាសាធារណៈស្តីពីការត្រួតពិនិត្យដិតដល់លើខ្សែសង្វាក់ផ្គត់ផ្គង់។</u>**

តម្រូវការនៃការត្រួតពិនិត្យដិតដល់មិនមានលក្ខណៈដូចគ្នាគ្រប់សហគ្រាសពហុជាតិនោះទេ ហើយគួរតែត្រូវបានធ្វើឡើងឱ្យស៊ីសង្វាក់ទៅតាមឧស្សាហកម្ម និងបរិបទនីមួយៗដែលខ្លួនធ្វើប្រតិបត្តិការ។ គិតមកដល់សព្វថ្ងៃនេះ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍបានតាក់តែងសេចក្តីណែនាំលើវិស័យនៃប្រតិបត្តិការធុរកិច្ចខុសៗគ្នាមួយចំនួន រាប់ចាប់ពីឧស្សាហកម្មទាញយកធនធានក្រោមដី រហូតដល់វិស័យហិរញ្ញវត្ថុ ប៉ុន្តែគោលការណ៍ណែនាំដែលទំនងជាពាក់ព័ន្ធខ្លាំងបំផុតនៅក្នុងវិស័យទាំងនេះក្នុងការតម្រូវឱ្យសហគ្រាសពហុជាតិដែលធ្វើប្រតិបត្តិការនៅកម្ពុជា គឺសេចក្តីណែនាំដែលធ្វើឡើងរវាងអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ និងអង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិសម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្មប្រកបដោយទទួលខុសត្រូវ ដែលសេចក្តីណែនាំនេះរួមបញ្ចូលផងដែរនូវឧបសម្ព័ន្ធជាក់លាក់អំពីការចូលរួមរបស់ជនជាតិដើមភាគតិច និងសេចក្តីព្រាងនៃការណែនាំស្តីពីខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយទទួលខុសត្រូវនៅក្នុងវិស័យសម្លៀកបំពាក់ និងស្បែកជើង។ សេចក្តីណែនាំទាំងនេះអាចជាធនធានដ៏មានតម្លៃសម្រាប់អង្គការសង្គមស៊ីវិល តាមរយៈការ

ដាក់ចេញនូវលក្ខខណ្ឌយ៉ាងច្បាស់លាស់ស្តីពីការអនុវត្តល្អបំផុត ដែលមានការទទួលស្គាល់ជាអន្តរជាតិដោយសហគ្រាសពហុជាតិ ដែលរំពឹងថានឹងត្រូវអនុវត្តតាម។

# ៤. គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់

## ៤.១ តើគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ គឺជាអ្វី?

គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ គឺជាគោលការណ៍ដែលទទួលស្គាល់ជាអន្តរជាតិដំបូងគេស្តីពីអភិបាលកិច្ចនៃការកាន់កាប់ ដែលសំដៅ**លើកកម្ពស់ការធានាសិទ្ធិកាន់កាប់ដោយសុវត្ថិភាព និងការទទួលបានដីធ្លី ជលផល និងព្រៃឈើស្មើភាពគ្នា សម្រាប់ជាមធ្យោបាយលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ ដែលគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងធ្វើឱ្យបរិស្ថានប្រសើរឡើង**។ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ លើកកម្ពស់អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធានជលផល និងធនធានព្រៃឈើ ដោយគោរពតាមគ្រប់ទម្រង់ទាំងអស់នៃការកាន់កាប់ ៖ ជាសាធារណៈ លក្ខណៈឯកជន សមូហភាព ជនជាតិដើមភាគតិច តាមប្រពៃណី និងក្រៅប្រព័ន្ធ។ គោលដៅសំខាន់បំផុតនៃគោលការណ៍ស្ម័គ្រចិត្តនេះ គឺដើម្បីសម្រេចឱ្យបាននូវសន្តិសុខស្បៀងសម្រាប់មនុស្សគ្រប់រូប ក៏ប៉ុន្តែទន្ទឹមនឹងគាំទ្រដល់ការខិតខំប្រឹងប្រែងលើការលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ក៏មានគោលបំណងរួមចំណែកដល់ការសម្រេចឱ្យបាននូវជីវភាពរបស់នៅប្រកបដោយចីរភាព ស្ថេរភាពសង្គម សន្តិសុខលំនៅដ្ឋាន ការអភិវឌ្ឍជនបទ ការការពារបរិស្ថាន និងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។ គោលការណ៍ស្ម័គ្រចិត្តនេះក៏មានគោលបំណងផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់រូបនៅគ្រប់ប្រទេសទាំងអស់ ទោះបីជាគោលការណ៍នេះសង្កត់ធ្ងន់តែទៅលើជនងាយរងគ្រោះ និងជនដែលមិនសូវទទួលបានការយកចិត្តទុកដាក់យ៉ាងណាក្តី។




**តើ "ការកាន់កាប់" ជាអ្វី?**

"ការកាន់កាប់" គឺជាទំនាក់ទំនងទៅនឹងដីធ្លី និងធនធានធម្មជាតិនៅលើដីធ្លី ក្នុងចំណោមមនុស្ស ក្នុងនាមជាបុគ្គល ឬជាក្រុម។ ទំនាក់ទំនងនេះអាចត្រូវបានកំណត់ដោយច្បាប់ (ឧទាហរណ៍ តាមរយៈកម្មសិទ្ធិដីធ្លី) ឬតាមរយៈប្រពៃណីទំនៀមទម្លាប់។ វិធាននៃការកាន់កាប់ ដូចជាតាមរយៈច្បាប់ភូមិបាលកំណត់អំពីរបៀបដែលសិទ្ធិកាន់កាប់លើដីធ្លីប្រព្រឹត្តទៅនៅក្នុងសង្គម។ ប្រព័ន្ធនៃការកាន់កាប់ដីធ្លីកំណត់អ្នកទាំងឡាយណាដែលអាចប្រើប្រាស់ធនធានសម្រាប់រយៈពេលណាមួយ និងក្រោមលក្ខខណ្ឌបែបណាខ្លះ។

*(ប្រភព ៖ អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ, "ការសិក្សាលើកទីបីអំពីការកាន់កាប់ដីធ្លី ៖ ការកាន់កាប់ដីធ្លី និងការអភិវឌ្ឍជនបទ" (ឆ្នាំ២០០២)* https://goo.gl/gJ7MsU *)*

## ៤.២ តើអង្គការសង្គមស៊ីវិលអាចប្រើប្រាស់គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់បានដោយរបៀបណា?

តាមរយៈការផ្ដល់សេចក្ដីណែនាំច្បាស់លាស់ និងជាក់ស្ដែងលើផ្នែកបច្ចេកទេស និងជំនាញនៃគោលនយោបាយ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់អាចប្រើជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជានៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រង និងការធ្វើអាជីវកម្មលើដីធ្លីឱ្យបានត្រឹមត្រូវ។

ដូចគ្នានឹងគោលការណ៍ណែនាំរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិដែរ គោលការណ៍ស្ម័គ្រចិត្តនេះមិនចងជាកាតព្វកិច្ចទេ ហើយគួរតែបំពេញបន្ថែម មិនមែនជំនួសឱ្យកាតព្វកិច្ចដែលមានស្រាប់ក្រោមច្បាប់ជាតិ និងអន្តរជាតិនោះទេ។ ប៉ុន្តែ វិសាលភាពនៃគោលការណ៍ស្ម័គ្រចិត្តនេះមានលក្ខណៈទូលាយជាងគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ ៖ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ មិនត្រឹមតែអាចប្រើដោយវិស័យធុរកិច្ចប៉ុណ្ណោះទេ តែថែមទាំងសម្រាប់**បុគ្គលគ្រប់រូបដែលមានការព្រួយបារម្ភអំពីបញ្ហាអភិបាលកិច្ចនៃការកាន់កាប់** រួមទាំងរដ្ឋាភិបាល អ្នកប្រើប្រាស់ដីធ្លី ជនជាតិដើមភាគតិច និងសង្គមស៊ីវិល។ គោលការណ៍ស្ម័គ្រចិត្តនេះក៏អនុវត្តជាសកលផងដែរ ដោយគោលការណ៍នេះអាចប្រើប្រាស់ដោយ និងនៅក្នុងប្រទេស និងគ្រប់តំបន់ទាំងអស់។

គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១ និងឆ្នាំ២០១២ ដោយគណៈកម្មាធិការសន្តិសុខស្បៀងពិភពលោករបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ ដោយមានការពិភាក្សាជាមួយភាគីពាក់ព័ន្ធរួមទាំងសង្គមស៊ីវិល និងធុរកិច្ច។ ដំណើរការដែលមានការចូលរួមសម្រាប់ការបង្កើតគោលការណ៍នេះ គឺជាភាពខ្លាំងមួយនៃគោលការណ៍ស្ម័គ្រចិត្តនេះ ក៏ដូចជាតួនាទីដ៏ចម្បងដែលគោលការណ៍ស្ម័គ្រចិត្តផ្ដល់ជូនអំពីសិទ្ធិស្ត្រី និងជនជាតិដើមភាគតិច។ ក៏ប៉ុន្តែ គោលការណ៍ស្ម័គ្រចិត្តនេះមិនចងជាកាតព្វកិច្ចផ្លូវច្បាប់ ហើយខុសពីគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិ គោលការណ៍ស្ម័គ្រចិត្តនេះមិនមានយន្តការដោះស្រាយបណ្ដឹងផ្ទាល់ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការ (មិន)អនុវត្តតាមនោះទេ។ ហេតុដូច្នេះ ខណៈដែលគោលការណ៍ស្ម័គ្រចិត្តនេះអាចផ្ដល់សេចក្ដីណែនាំដ៏មានប្រយោជន៍ដល់ស្ថាប័ននានាអំពីរបៀបដោះស្រាយបញ្ហាកាន់កាប់ដីធ្លីប្រកបដោយការទទួលខុសត្រូវ គោលការណ៍ស្ម័គ្រចិត្តនេះអាចមានប្រសិទ្ធភាពតិចជាងនៅពេលបំពេញតាមសសរស្ដម្ភទី ៣ នៃក្របខណ្ឌរបស់អង្គការសហប្រជាជាតិស្ដីពីធុរកិច្ចនិងសិទ្ធិមនុស្ស ៖ ការផ្ដល់ដំណោះស្រាយ។

ដូច្នេះ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់អាចមានប្រយោជន៍បំផុតសម្រាប់អង្គការសង្គមស៊ីវិលសម្រាប់ជាឯកសារយោងនៅពេលធ្វើការពាក់ព័ន្ធជាមួយនឹងធុរកិច្ច និងរដ្ឋាភិបាល ដោយហេតុថាគោលការណ៍ស្ម័គ្រចិត្តនេះកំណត់យ៉ាងច្បាស់អំពីបទដ្ឋានដែលស្ថាប័នទាំងអស់ត្រូវបានរំពឹងទុកថានឹងអនុលោមតាមនៅពេលដោះស្រាយជាមួយនឹងបញ្ហាអភិបាលកិច្ចផ្នែកដីធ្លី។ ដោយសារគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ជាលិខិតុបករណ៍សកលដែលបានបង្កើតដោយស្ថាប័នរបស់អង្គការសហប្រជាជាតិ ដោយមានការឯកភាពពីសំណាក់ដៃគូពាក់ព័ន្ធសំខាន់ៗ យើងនិយាយបានថាគោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់មានការទទួលស្គាល់ និងភាពត្រឹមត្រូវតាមច្បាប់ក្នុងកម្រិតខ្ពស់ ដែលអាចផ្តល់ទម្ងន់បន្ថែមទៅលើយុទ្ធនាការរបស់អង្គការសង្គមស៊ីវិលក្នុងការផ្លាស់ប្តូរឥរិយាបថរបស់ក្រុមហ៊ុន ឬដោះស្រាយបញ្ហារំលោភបំពានសិទ្ធិមនុស្សដោយវិស័យធុរកិច្ច។ ការផ្តោតរបស់គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ទៅលើជនជាតិដើមភាគតិចក៏ធ្វើឱ្យគោលការណ៍ណែនាំនេះរឹតតែជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់បង្កើនការយល់ដឹងក្នុងចំណោមជនជាតិដើមភាគតិចអំពីសិទ្ធិដែលពួកគាត់មានលើដីធ្លីផងដែរ។

## ៤.៣ ការប្រើប្រាស់គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ ដើម្បីការពារសិទ្ធិមនុស្ស

គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ផ្តល់តួនាទីដ៏ចម្បងមួយដល់ការការពារសិទ្ធិមនុស្ស។ នៅក្នុងជំពូកស្តីពីបញ្ហាទូទៅ គោលការណ៍ស្ម័គ្រចិត្តនេះក្រើនរម្លឹកឡើងវិញយ៉ាងច្បាស់ពីកាតព្វកិច្ចរបស់រដ្ឋក្រោមលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្សដែលមានជាធរមាន។

ក៏ប៉ុន្តែ ខណៈដែលអនុសាសន៍ជាច្រើនសំដៅផ្ទាល់ទៅលើរដ្ឋ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ក៏ទទួលស្គាល់អំពីទំនួលខុសត្រូវរបស់តួអង្គមិនមែនរដ្ឋផងដែរ រួមទាំងសហគ្រាសធុរកិច្ច ដោយចែងយ៉ាងច្បាស់ថាតួអង្គទាំងនោះ *"មានការទទួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ដីស្របច្បាប់។"* ស្រដៀងគ្នានឹងគោលការណ៍របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍសម្រាប់សហគ្រាសពហុជាតិដែរ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការសៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើ

ការកាន់កាប់ចែងថាសហគ្រាសធុរកិច្ច *"ត្រូវប្រតិបត្តិការប្រកបដោយការយកចិត្តទុកដាក់ខ្លាំង ដើម្បីបញ្ចៀសការបំពានលើសិទ្ធិមនុស្ស និងសិទ្ធិកាន់កាប់ដីស្របច្បាប់របស់អ្នកដទៃ។"*

ដើម្បីការអនុវត្តសិទ្ធិ និងការទទួលខុសត្រូវទាំងនេះ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់លើកឡើងពីគោលការណ៍ចំនួន ១០ ចំណុចដែលមានសារៈសំខាន់ក្នុងការរួមចំណែកដល់អភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ដីធ្លី ៖




## ៤.៤ អភិបាលកិច្ចល្អនៃការកាន់កាប់ក្នុងស្ថានភាពជាក់ស្តែង

ជំពូកបន្ទាប់ៗរៀបរាប់ពីគោលការណ៍ទូទៅទាំងនេះ និងផ្តល់នូវសេចក្តីណែនាំលម្អិតបន្ថែមទៀតស្តីពីវិធីដែលជំពូកទាំងនេះគួរតែត្រូវបានទទួលស្គាល់នៅក្នុងបរិបទជាក់ស្តែង។ ក្នុងករណីនេះ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់អាចធ្វើជាសេចក្តីយោងក្នុងការអនុវត្តជាក់ស្តែងដ៏មានប្រយោជន៍មួយ សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងការងាររបស់ខ្លួនក្នុងករណីជាក់លាក់នីមួយៗដើម្បីធ្វើការជួសមុខឱ្យបុគ្គល និងក្រុមជាក់លាក់ណាមួយដែលសិទ្ធិមនុស្សរបស់អ្នកទាំងនោះត្រូវទទួលរងផលប៉ះពាល់អវិជ្ជមានពីវិស័យធុរកិច្ច។ មានផ្នែកជាច្រើនដែលពាក់ព័ន្ធជាពិសេស និងមានប្រយោជន៍នៅក្នុងបរិបទកម្ពុជា។ ឧទាហរណ៍ចំនួន ៣ ត្រូវបានលើកឡើងដូចតទៅ ៖

គោលការណ៍ទី៣.៩ ៖ ជនជាតិដើមភាគតិច និងសហគមន៍ផ្សេងៗដែលមានប្រព័ន្ធកាន់កាប់ដីធ្លីតាមបែបប្រពៃណី

នៅកម្ពុជា ជនជាតិដើមភាគតិចនៅតែបន្តទទួលរងការរំលោភសិទ្ធិមនុស្សតាមរយៈការផ្ទេរដីមិនស្របច្បាប់របស់ពួកគាត់ ការបណ្ដេញចេញដោយបង្ខំ និងការបំផ្លិចបំផ្លាញបរររកស៊ីរបស់ពួកគាត់។ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់បានរួមបញ្ចូលទាំងអនុសាសន៍ដែលរដ្ឋ និងតួអង្គមិនមែនរដ្ឋទទួលស្គាល់ថាដីធ្លី ជលផល និងព្រៃឈើមានតម្លៃផ្នែកសង្គម វប្បធម៌ ជំនឿ សេដ្ឋកិច្ច បរិស្ថាន និងនយោបាយទៅដល់ជនជាតិដើមភាគតិច ហើយរដ្ឋគប្បីត្រូវផ្ដល់ការទទួលស្គាល់ឱ្យបានត្រឹមត្រូវ និងការពារសិទ្ធិកាន់កាប់ដីស្របច្បាប់របស់ជនជាតិដើមភាគតិចឱ្យស្របជាមួយនឹងកាតព្វកិច្ច ដែលមានស្រាប់ក្រោមច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងរដ្ឋ និងភាគីផ្សេងទៀតគប្បីត្រូវប្រឹក្សាយោបល់ជាមួយជនជាតិដើមភាគតិចដោយភាពស្មោះត្រង់មុននឹងចាប់ផ្ដើមគម្រោងណាមួយ។ នៅក្នុងបរិបទនេះ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់រួមបញ្ចូលនូវសេចក្ដីយោងអំពីទស្សនៈនៃការយល់ព្រមដោយសេរី ជាមុន និងទទួលបាននូវការជូនដំណឹង ដែលដកស្រង់ចេញពីសេចក្ដីប្រកាសស្ដីពីសិទ្ធិជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ និងទទួលស្គាល់ថាជាបទដ្ឋានសំខាន់មួយសម្រាប់ការប្រឹក្សាយោបល់ប្រកបដោយប្រសិទ្ធភាព និងមានអត្ថន័យជាមួយនឹងជនជាតិដើមភាគតិច។

គោលការណ៍ទី១៦ ៖ អស្សាមិករណ៍[9] និងសំណង

ដោយសារតែមានការបណ្ដេញចេញដោយបង្ខំនៅកម្ពុជាចេះតែបន្តកើតមាន គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់អាចផ្ដល់សេចក្ដីណែនាំដ៏មានប្រយោជន៍អំពីវិធីបញ្ចៀសការរំលោភបំពានសិទ្ធិមនុស្សបែបនេះ ដែលអាចកើតមាននាពេលអនាគត។ ដោយឡែក គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្ដីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ផ្ដល់អនុសាសន៍ថានៅក្នុងករណីអស្សាមិករណ៍ រដ្ឋគប្បីត្រូវធានាអំពីការវាយតម្លៃដ៏ត្រឹមត្រូវ និងការផ្ដល់សំណងភ្លាមៗដោយអនុលោមតាមច្បាប់ជាតិ រដ្ឋគប្បីត្រូវខ្នះខ្នែងបង្ការអំពើពុករលួយ និងអ្វី

[9] មាត្រា ៤ នៃច្បាប់ស្ដីពីអស្សាមិករណ៍ឆ្នាំ២០១០ ៖ អស្សាមិករណ៍ សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនាស្ដារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្ដល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌។

ដែលសំខាន់ រាល់ការបណ្តេញចេញ និងការប្តូរកន្លែងតាំងលំនៅមិនគួរបណ្តាលឱ្យបុគ្គលប្រែជាគ្មានផ្ទះសម្បែង ឬក្លាយជាជនងាយរងគ្រោះអំពីការរំលោភបំពានសិទ្ធិមនុស្សនោះទេ។

<u>គោលការណ៍ទី២៥ ៖ ទំនាស់ទាក់ទងនឹងសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើ</u>

ដោយមានការផ្លាស់ទីជម្រកទូទាំងប្រទេស និងការបំផ្លិចបំផ្លាញប័ណ្ណកម្មសិទ្ធិដីធ្លីក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅកម្ពុជា ដែលករណីនេះនៅតែប៉ះពាល់ដល់អភិបាលកិច្ចនៃការកាន់កាប់ដីនៅក្នុងព្រះរាជាណាចក្រមួយនេះនាពេលបច្ចុប្បន្ននោះ អនុសាសន៍ដែលពាក់ព័ន្ធនឹងទំនាស់ក៏មានសារៈសំខាន់ផងដែរ។ គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀងនិងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើការកាន់កាប់ផ្តល់អនុសាសន៍ថា រដ្ឋ *"ធានាថារាល់បញ្ហានៃការកាន់កាប់ត្រូវបានដោះស្រាយមុនពេល ក្នុងអំឡុងពេល និងក្រោយពេលមានទំនាស់"* និងថាដោយសារមូលហេតុទំនាស់ កន្លែងណាដែលពុំមានការកត់ត្រាអំពីការកាន់កាប់ដីជាផ្លូវការទេនោះ សិទ្ធិកាន់កាប់ដីដែលមានស្រាប់គប្បីត្រូវចងក្រងទុកជាឯកសារឱ្យបានល្អបំផុតតាមដែលអាចធ្វើទៅបានដោយឈរលើការគិតគូរដល់បញ្ហាយែនឌ័រ រួមទាំងតាមរយៈការពិនិត្យមើលពីប្រវត្តិ និងសក្ខីកម្មផ្ទាល់មាត់។

# ឯកសារយោង


ម.ស.ម.ក, 'កម្ពុជា ៖ ដីមានជម្លោះ ទិដ្ឋភាពនៃស្ថានភាពដីធ្លី' (របាយការណ៍)( ខែធ្នូ ឆ្នាំ២០១៣) https://goo.gl/QPh8sa

ម.ស.ម.ក, 'បរាជ័យនៃយន្តការដោះស្រាយទំនាស់ដីធ្លី' (កំណត់ត្រាសង្ខេប) (ខែកក្កដា ឆ្នាំ២០១៤) https://goo.gl/js0guS

អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ, "ការសិក្សាលើកទីបីអំពីការកាន់កាប់ដីធ្លី ៖ ការកាន់កាប់ដីធ្លី និងការអភិវឌ្ឍជនបទ" (ឆ្នាំ២០០២) https://goo.gl/gJ7MsU

អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិ, "គោលការណ៍ស្ម័គ្រចិត្តរបស់អង្គការស្បៀង និងកសិកម្មរបស់សហប្រជាជាតិស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវលើសិទ្ធិកាន់កាប់ដីធ្លី ធនធាននេសាទ និងធនធានព្រៃឈើនៅក្នុងបរិបទសន្តិសុខស្បៀង" (ឆ្នាំ២០១២) https://goo.gl/EHPEz2

អង្គការឃ្លាំមើលសិទ្ធិមនុស្ស, '"ធ្វើការឱ្យលឿន ឬឈប់ធ្វើការ" ការរំលោភសិទ្ធិការងារនៅក្នុងឧស្សាហកម្មកាត់ដេរក្នុងប្រទេសកម្ពុជា' (ខែមិនា ឆ្នាំ២០១៥) http://bit.ly/1NAZeEk

អង្គការប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ, "គោលការណ៍សម្រាប់សហគ្រាសពហុជាតិ" (កំណែឆ្នាំ២០១១), ជំពូកទី៦ http://bit.ly/1kPDOqW

អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ, "ការអនុវត្តគោលការណ៍សម្រាប់សហគ្រាសពហុជាតិ ៖ ស្ថាប័នបង្គោលថ្នាក់ជាតិពីឆ្នាំ២០០០ ដល់ឆ្នាំ២០១៥" (ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦) http://bit.ly/29eOCif

ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា, 'គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស ៖ ការអនុវត្តក្របខណ្ឌអង្គកាសហប្រជាជាតិស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ"' (ខែធ្នូ ឆ្នាំ២០១១) https://goo.gl/WE3OWm

បណ្ឌិត សាយ បូរី, "នីតិរដ្ឋបាលទូទៅ" (បណ្ណាគារ អង្គរ បោះពុម្ពលើកទី៤ ឆ្នាំ២០១២)